

# ការកំណត់អត្តសញ្ញាណ និង ឆ្លើយតបចំពោះការបីផ្លែងទ្រង់ទ្រាយហូឡូខសត៍ ៖

## មេរៀនអាស៊ីអាគ្នេយ៍

On the cover: Tuol Sleng Genocide Museum (Credit: Rafal Pankowski)

# CONTENTS

## IDENTIFYING AND COUNTERING HOLOCAUST DISTORTION: LESSONS FOR AND FROM SOUTHEAST ASIA


Introduction

*What is Holocaust Denial and Distortion?*

១. What is Holocaust denial?

២. What do Holocaust deniers claim?

៣. What is Holocaust distortion and why it is different from denial?

៤. Holocaust distortion in Eastern Europe

Critical Debate Over Jan T. Gross` books

Early ២000s ២០១២ ២០១៧

Why the debate about Gross` books is important?

៥. Is the Holocaust comparable? How can we avoid banalisation, instrumentalization of victims, trivialisation in comparison?

៦. How can we resist Holocaust deniers?

Irving Trial


## COUNTRY FACT SHEETS (PROFILES) CAMBODIA


១. Background and context

Basic facts about the modern history of Cambodia and the main cases of mass violence

Historiography: the main themes and elements of memorialisation

The role of Cambodia in the Second World War, memorialisation of the Second World War: does it exist? In what forms?

Aspects of social diversity, the main minorities in the country, cases of persecution after ១៩៤៥

២. Existing types of Holocaust and genocide denial and distortion

Multideniers

Khieu Samphan | Jacques Verges | Jan Myrdal |Israel Shamir|Naom Chomsky

Potential local tools for Cambodia to counter denial and distortion:

The issue of responsibility and resistance against the Khmer Rouge

Stories of minority women`s resilience and resistance under the Khmer Rouge

State and nongovernmental initiatives to prevent/counter denial

Examples of civil society initiatives





All titles are clickable!

# CONTENTS


## COUNTRY FACT SHEETS (PROFILES) MYANMAR (BURMA)

### ๑. Background and context

Basic facts about the modern history of Myanmar and the main cases of mass violence

Information about historiography: the main themes, the key elements of memorialisation

The role of the country in the Second World War; memorialisation of the Second World War - does it exist? In what forms?

The Burma-Thailand railway

### ๒. Existing types of Holocaust and genocide denial and distortion

The existing culture of denial around the Rohingya people and denial of atrocities against the Rohingya

Nazi symbols

### ๓. What themes from contemporary history are relevant to our work against Holocaust and genocide denial and distortion?

Jews as part of a pluralist society in Myanmar

Who were the first Jews in Burma?

Who were the Baghdadi Jews?

What was the position of Jews in Burmese society during the British rule?

Diversity of the Jewish Community in Burma

What happened during the Second World War?

### ๔. The Samuels Family

Today`s Community

Local resistance

The White Rose Campaign




## សេចក្តីផ្តើម

ពិព័រណ៍ស្តីពី ការកំណត់អត្តសញ្ញាណ និងឆ្លើយតបចំពោះការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍៖ មេរៀនសម្រាប់និងពីអាស៊ីអាគ្នេយ៍ ផ្តួចផ្តើមចេញពីបទពិសោធន៍អំពីហូឡូខស្សរបស់ជនជាតិប៉ូឡូញ និងនៅអឺរ៉ុបខាងកើត និងបន្ថែមបទពិសោធន៍ពីកេរតំណែល ប្រវត្តិសាស្ត្រជាតិ និងក្នុងតំបន់អាស៊ីអាគ្នេយ៍ តាមរយៈការឆ្លុះបញ្ចាំងដោយផ្តោតលើប្រទេសកម្ពុជា ប្រទេសភូមា និងប្រទេសថៃ។

ខណៈពេលដែលអាស៊ីអាគ្នេយ៍ឆ្លងកាត់បទពិសោធន៍រួម ជាសកលនូវសង្គ្រាមលោកលើកទីពីរ ជាមួយនឹងអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត តំបន់នីមួយៗមានបទពិសោធន៍ដោយឡែកផ្សេងៗគ្នា។ ហូឡូខសត៍ បានប្រព្រឹត្តឡើងជាចម្បងនៅលើទឹកដីអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត នៅចន្លោះឆ្នាំ១៩៣៣ ដល់ឆ្នាំ១៩៤៥ ដោយពួកណាហ្ស៊ីអាល្លឺម៉ង់ និងបក្ខពួករួមសហការ បានធ្វើឲ្យជនជាតិជ្វីហ្វនៅអឺរ៉ុបចំនួនប្រាំមួយលាននាក់បានស្លាប់បាត់បង់ជីវិតនៅក្នុងជំរុំមរណៈ ឬត្រូវសម្លាប់នៅនឹងកន្លែង។ អឺរ៉ុបខាងកើត ដែលធ្លាប់រងនៅក្រោមរបបកុម្មុយនីស្ត និងផ្តាច់ការ ត្រូវបង្ខំឲ្យត្រឡប់ទៅប្រឈមនឹងអតីតកាលដ៏លំបាកវិញទៀត រួមមានទាំងការចូលរួមជជែកវែកញែកដ៏តានតឹងរបស់អ្នកដែលមានតួនាទីនៅក្នុងតំបន់របស់ខ្លួនកាន់កាប់ផ្ទាល់ នៅអំឡុងពេលហូឡូខស្ស អ្នកខ្លះជាអ្នកចូលដៃរួមសហការ ខ្លះទៀតជាអ្នកឃើញហេតុការណ៍ និងអ្នកជួយសង្គ្រោះ និងអន្តរាគមន៍។

ទោះបីជាបទពិសោធន៍អាស៊ីអាគ្នេយ៍ទាក់ទងនឹងសង្គ្រាមលោកលើកទីពីរ រួមបញ្ចូលការកាន់កាប់របស់ជប៉ុន ព្រមទាំងជម្លោះផ្សេងៗ និងអំពើប្រល័យពូជសាសន៍ក៏ដោយ ក៏ការយល់ដឹងអំពីហូឡូខស្សនៅមានកម្រិតទាប។ នេះជាហេតុនាំឲ្យមាននូវការបំផ្លែងទ្រង់ទ្រង់ និងគិតថាជារឿងមិនសំខាន់។ ក្រៅពីការព្រងើយកន្តើយ មិនយកចិត្តទុកដាក់នឹងប្រវត្តិសាស្ត្រ និងពុំមានការយល់ដឹងអំពីប្រវត្តិសាស្ត្រហូឡូខសត៍ ព្រមទាំងអសមត្ថភាពក្នុងការដាក់ហូឡូខសត៍ជាមេរៀនសកលនៅបរិបទមិនមែនអឺរ៉ុបនោះ មានឧទាហរណ៍ជាច្រើន បានបង្ហាញពីបំផ្លែងទ្រង់ទ្រាយហូឡូខស្សជាសាធារណៈ និងតាមសារព័ត៌មាន។

តាមរយៈការចែករំលែកបទពិសោធន៍ និងផ្តល់នូវសម្ភារ និងការពិភាក្សាដើម្បីដោះស្រាយពីបញ្ហាបំផ្លែងទ្រង់ទ្រាយហូឡូខស្ស ដោយផ្អែកលើការជជែកពីអឺរ៉ុបខាងកើត ពិព័រណ៍នេះ មានគោលបំណងជំរុញឲ្យមានការនិយាយវិភាគទាក់ទងនឹងកេរតំណែលពីអំពើប្រល័យពូជសាសន៍ នៅអាស៊ីអាគ្នេយ៍។

សមាគមមានគោលដៅលុបបំបាត់ការបំផ្លែងទ្រង់ទ្រាយ ការធ្វើឲ្យបាត់ខ្លឹមសារ និងការបដិសេធន៍អំពីហូឡូខសត៍ និងអំពើប្រល័យពូជសាសន៍ផ្សេងៗទៀត ដើម្បីបញ្ជាក់សារៈសំខាន់អំពីហូឡូខសត៍ ជាតំណែលសកល និងជាចំណុចយោងមួយនៅក្នុងការជជែកពិភាក្សាអំពីសិទ្ធិមនុស្សនាសម័យបច្ចុប្បន្ននេះ។ យើងយល់ឃើញថាការបដិសេធន៍ និងការបំផ្លែងទ្រង់ទ្រាយអំពើប្រល័យពូជសាសន៍ ជាទម្រង់មួយនៃការស្អប់ខ្ពើមដែលជំរុញឲ្យដល់ភាពអមនុស្សធម៌ចំពោះជនរងគ្រោះ ជាទម្រង់មួយដែលត្រូវប្រើដើម្បីបង្ហាញពីការរើសអើង និងអំពើហិង្សាប្រឆាំងនឹងជនជាតិភាគតិចផ្សេងៗទៀត។

ពិពរណ៍តាមប្រព័ន្ធឌីជីថលនេះ រួមមានសម្ភារៈ ឯកសារពីបណ្ណាសារដ្ឋានរបស់ សមាគម NEVER AGAIN ដែលទទួលបានមកពីការប្រមូលចងក្រង និងការចូលរួម ចំណែកផ្តល់ឲ្យពីសហការីរបស់យើង នៅអាស៊ីអាគ្នេយ៍។

"NEVER AGAIN" ASSOCIATION

**Supported by**
INTERNATIONAL HOLOCAUST REMEMBRANCE ALLIANCE
**Heinrich Boell Stiftung Cambodia**

**អ្នកចូលរួមក្នុងការបង្កើតពិព័រណ៍៖ វេន ឡាប្ជិ បារូ (វត្តព្រះពុទ្ធ Phrmarangsi ប្រទេសថៃ) រ៉ូណាន លី (សកលវិទ្យាល័យ Loughborough ប្រទេសអង់គ្លេស) Rafal Pankowski (សមាគម NEVER AGAIN ប្រទេសប៉ូឡូញ) Sammy Samuels (សហគមន៍ជ្វីហ្វ ប្រទេសភូមា) Natalia Sineaeva (សមាគម NEVER AGAIN ប្រទេសប៉ូឡូញ) សើ សាយ្យាណា (វិទ្យាស្ថានសន្តិភាព ប្រទេសកម្ពុជា) Verita Sriratana (សកលវិទ្យាល័យ Chulalongkorn ប្រទេសថៃ) Thet Swe Win (Synergy ប្រទេសភូមា)**
**អ្នកបកប្រែ៖ សើ សាយ្យាណា (ភាសាខ្មែរ ) Hay Mann Zu Zue, Khine Wai Lwn, និង Yaya (David) Aye Myat (ភាសាភូមា) Wirakam Salmand (ភាសាថៃ)**

**អ្នកពិនិត្យកែសម្រួល៖ Kevin McRobb (ប្រទេសអង់គ្លេស/ប៉ូឡូញ)**

**អ្នករចនាពិព័រណ៍ (PDF)៖ Andrey Sergunkin (បូជណីយដ្ឋាន ប្រទេសរុស្ស៊ី/ប៉ូឡូញ)**
**អ្នករចនាពិព័រណ៍៖ Dmitrii Arikov (Eco-Tiras ម៉ូឡូវ៉ា), Vitalii Boico (Eco-Tiras ម៉ូឡូវ៉ា)**

www.neveragainassociation.org
www.holocaustEducation-asia.org
www.holocaustremembrance.com

# តើការបំផ្លែងទ្រង់ទ្រាយ និងបដិសេធអំពីហូឡូខសត៍ (HOLOCAUST) ជាអ្វី?

**អំពីការកំណត់និយមន័យនៃការបដិសេធន៍ និងបំផ្លែងទ្រង់ទ្រាយHolocaust ដោយសម្ព័ន្ធចងចាំHolocaustអន្តរជាតិ (IHRA)**

សមាជិកនៃសម្ព័ន្ធចងចាំHolocaustអន្តរជាតិ (IHRA) ចំនួន៣១ប្រទេស បានយល់ព្រមកំណត់យកអត្ថន័យស្តីពីការបដិសេធន៍ និងបំផ្លែងទ្រង់ទ្រាយ នៅក្នុងសម័យប្រជុំអង្គរបស់សម្ព័ន្ធ IHRA នាទីក្រុងតូរ៉ង់តូ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣។

ការឲ្យនិយមន័យនេះ បានបង្កើតឡើងដោយក្រុមអ្នកជំនាញរបស់សម្ព័ន្ធ IHRA នៅក្នុងគណ:កម្មាធិការស្តីពីលទ្ធិប្រឆាំងនឹងជនជាតិជ្វីហ្វ និងការបដិសេធន៍Holocaust ដោយមានការសហការជាមួយនឹងតំណាងរដ្ឋាភិបាលនៃប្រទេសជាសមាជិក ដើម្បីប្រើជាឧបករណ៍កំណត់អត្ថន័យ។

ការឲ្យនិយមន័យនៃការបំផ្លែងទ្រង់ទ្រាយ និងបដិសេធអំពីHolocaust និយមន័យដែលកំណត់ឡើងនេះ គឺជាការបង្ហាញឲ្យដឹងថាការបដិសេធន៍ និងបំផ្លែងទ្រង់ទ្រាយHolocaust ត្រូវតែជំទាស់ប្រឆាំងក្នុងកម្រិតជាតិ និងអន្តរជាតិ និងទាមទារការពិនិត្យសិក្សាជាលក្ខណ:សកល។ ក្នុងន័យនេះ សម្ព័ន្ធ IHRA កំណត់អត្ថន័យនៃកន្សោមពាក្យជានិយមន័យសម្រាប់ការប្រើប្រាស់ជាឧបករណ៍ក្នុងការអនុវត្តន៍ប្រតិបត្តិការ ដោយមិនពាក់ព័ន្ធនឹងផ្លូវច្បាប់។

ការបដិសេធន៍អំពីHolocaust គឺជាការនិយាយ និងឃោសនាដែលបដិសេធនឹងការពិតជាប្រវត្តិសាស្រ្ត និងបដិសេធចំពោះការប្រល័យពូជសាសន៍ជនជាតិជ្វីហ្វ ដោយពួកណាហ្ស៊ី និងអ្នកសមគំនិត នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ ដែលហៅថា Holocaust ឬ Shoah។ ការបដិសេធន៍អំពីHolocaust សំដៅជាក់លាក់ទៅលើការប៉ុនប៉ងណាមួយ ដែលអះអាងថា Holocaust/Shoah មិនបានកើតឡើង។

ការបដិសេធន៍អំពីHolocaust អាចមានជាការបដិសេធន៍ជាសាធារណ: ឬជាការបង្កមន្ទិលចំពោះការប្រើវិធីបំផ្លិចបំផ្លាញ (ដូចជា បន្ទប់ឧស្ម័នពុល ការបាញ់សម្លាប់ជាក្រុម បង្អត់អាហារ និងទារុណកម្ម) ឬចេតនាប្រល័យពូជសាសន៍ជាជាតិជ្វីហ្វ។

ការបដិសេធន៍អំពីHolocaust ក្នុងទម្រង់ផ្សេងៗ គឺជាការបង្ហាញពីការប្រឆាំងនឹងជនជាតិជ្វីហ្វ។ ការប៉ុនប៉ងបដិសេធអំពីការប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វ គឺជាការព្យាយាមដោះលែងអ្នកលទ្ធិសង្គមជាតិនិយម និងលទ្ធិប្រឆាំងនឹងជនជាតិជ្វីហ្វ ឲ្យរួចពីទោសកំហុស ឬការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ទៅលើប្រជាជនជ្វីហ្វ។ ទម្រង់បដិសេធអំពីHolocaust រួមបញ្ចូលទាំងការបន្ទោសជនជាតិជ្វីហ្វពីការបំផ្លើស ឬបង្កើតShoah ដើម្បីផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ហិរញ្ញវត្ថុ ដែលហាក់ដូច Shoah គឺជាលទ្ធផលពីការឃុបឃិតរៀបចំដោយជនជាតិជ្វីហ្វ។ ការធ្វើដូច្នេះ គឺជាចេតនាដែលមានគោលដៅដាក់កំហុសឲ្យជនជាតិជ្វីហ្វ និងធ្វើឲ្យលទ្ធិប្រឆាំងជនជាតិជ្វីហ្វ មានលក្ខណ:ស្របច្បាប់ម្តងទៀត។

ជាញឹកញាប់ គោលដៅនៃការបដិសេធន៍អំពីHolocaust គឺជាការស្តារឲ្យមានឡើងវិញដោយបើកចំហរនូវលទ្ធិប្រឆាំងជនជាតិជ្វីហ្វ និងជំរុញនូវមនោគមវិជ្ជានយោបាយ និងលក្ខខណ្ឌនានា ដែលអំណោយផលដល់ការផ្តើមឲ្យមានព្រឹត្តិការណ៍បដិសេធនោះ។

## ការបំផ្លែងអំពីHolocaust សំដៅលើ៖

**១) ការព្យាយាមប៉ុនប៉ងដោះសារ ឬសម្រាលផលប៉ះពាល់នៃHolocaust ឬធាតុសំខាន់ៗ ដែលមានអ្នកចូលរួមសហការ និងសម្ព័ន្ធមិត្តរបស់ណាហ្ស៊ីអាល្លឺម៉ង់។**
**២) ការបន្ថយចំនួនអ្នករងគ្រោះដោយHolocaust ទាំងអស់ ដែលផ្ទុយខុសពីចំនួនដែលមានប្រភពត្រឹមត្រូវ។**
**៣) ការប៉ុនប៉ងទិះទៀនបន្ទោសជនជាតិជ្វីហ្វថាជាអ្នកបង្កឲ្យមានអំពើប្រល័យពូជសាសន៍ដោយខ្លួនឯង។**
**៤) សេចក្តីថ្លែងការណ៍ដែលយល់ថាHolocaust ជាព្រឹត្តិការណ៍ប្រវត្តិសាស្រ្តវិជ្ជមានមួយ។ សេចក្តីថ្លែងការណ៍ទាំងនេះមិនមែនជាការបដិសេធន៍អំពីHolocaust ទេ ប៉ុន្តែជាប់ទាក់ទងខ្លាំងតាមទម្រង់ជាឬសគល់នៃលទ្ធិប្រឆាំងនឹងជនជាតិជ្វីហ្វ ដែលអាចនិយាយថា Holocaustមិនបានឈានទៅដល់ថ្នាក់ សម្រេចតាមគោលដៅគម្រោង «ដំណោះស្រាយចុងក្រោយពីបញ្ហាជនជាតិជ្វីហ្វ» នោះទេ។**
**៥) ការប៉ុនប៉ងបិទបាំងការទទួលខុសត្រូវលើការបង្កើតជំរុំប្រមូលផ្តុំ និងជំរុំមរណ: ដែលរៀបចំគ្រប់គ្រង និងប្រតិបត្តិដោយណាហ្ស៊ីអាល្លឺម៉ង់ ដោយដាក់កំហុសទៅលើជាតិសាសន៍ ឬក្រុមជាតិពន្ធុដទៃ។**

## តើការបដិសេធហូឡូខូសត៍ជាអ្វី?

ការបដិសេធគឺជាលក្ខណៈទូទៅនៃអំពើប្រល័យពូជសាសន៍។ ជនដៃដល់ខ្លួនឯង ច្រើនតែជាអ្នកដែលបដិសេធ ដោយសារពួកគេព្យាយាមលុបបំបាត់អំពើឧក្រិដ្ឋរបស់ខ្លួន។

«ឃ្លាំមើលអំពើប្រល័យពូជសាសន៍» បានបញ្ចូល «ការបដិសេធ» ទៅក្នុងដំណាក់កាលទាំង១០នៃអំពើប្រល័យពូជសាសន៍។ លោកបានសរសេរថា៖

**«ការបដិសេធ គឺជាដំណាក់កាលចុងក្រោយបង្អស់ ដែលមានតាំងពីដំណាក់កាលដំបូងរហូតមក ហើយអំពើប្រល័យពូជសាសន៍តែងតែកើតមានបន្ទាប់ពីនេះ។ ការបដិសេធ គឺជាសូចនាករដ៏ប្រាកដមួយដែលបញ្ជាក់យ៉ាងច្បាស់អំពីការបន្តសម្លាប់រង្គាលនៃអំពើប្រល័យពូជសាសន៍។ ជនដៃដល់នៃអំពើប្រល័យពូជសាសន៍ ជីកគាស់រណ្តៅសាកសព ដុតសាកសព ដើម្បីព្យាយាមបិទបាំងភស្តុតាង និងគំរាមបំភ័យសាក្សី។ ពួកគេបដិសេធថាមិនបានប្រព្រឹត្តអំពើឧក្រិដ្ឋអ្វីឡើយ និងតែងតែបន្ទោសជនរងគ្រោះចំពោះរឿងដែលបានកើតឡើង។ ពួកគេរារាំងការស៊ើបអង្កេតពីបទល្មើស និងបន្តរហូតទាល់បង្ខំឲ្យចាកចេញ នៅពេលពួកគេគេចធ្វើនិរទេសខ្លួនទៅនៅក្រៅប្រទេស។ នៅទីនោះ ពួកគេនៅតែគ្មានទោស ដូចជា ប៉ុល ពត ឬ Adi Amin លុះត្រាតែពួកគេត្រូវចាប់ខ្លួន និងបង្កើតុលាការដើម្បីកាត់ក្តីពួកគេ[១]?**

ដូចគ្នានេះដែរ ប្រភពដើមនៃការបដិសេធអំពីហូឡូខស្ត អាចរកឃើញក្នុងចំណោមជនដៃដល់ទាំងនោះ គឺជា ណាហ្ស៊ី។ ពួកគេប៉ុនប៉ងលុបបំបាត់ភស្តុតាងនៃអំពើឧក្រិដ្ឋរបស់ពួកគេ នៅក្នុងអំឡុងពេលហូឡូខស្ត។ គ្មានបទបញ្ជាសរសេរជាលាយលក្ខណ៍អក្សរចេញពីហ៊ីត្លែរ ឲ្យសម្លាប់ជនជាតិជ្វីហ្វឡើយ គឺពួកជនដៃដល់ប្រើពាក្យសម្ងាត់ និងឃ្លាសម្រាយ ដូចជា ដើម្បីបិទបាំងការសម្លាប់នោះ "Aussiedlung" (ជម្លៀស) "Abschiebung" (បញ្ជូនចេញ) និង "Endloesung" (ដំណោះស្រាយចុងក្រោយ)។

ពួកណាហ្ស៊ី បានរៀបចំយុទ្ធនាការសម្ងាត់កងសកម្ម ១០០៥ (Unit Action ១០០៥) ពីខែមិថុនា ឆ្នាំ១៩៤២ រហូតដល់ចុងឆ្នាំ១៩៤៤ ដើម្បីបំផ្លាញភស្តុតាងអំពីឃាតកម្មទ្រង់ទ្រាយធំ ដែលបានកើតឡើងក្រោម «ប្រតិបត្តិការ រ៉ែនហាត» ក្នុងគោលដៅសម្លាប់បំបាត់ជនជាតិជ្វីហ្វទាំងអស់ដែលនៅអឺរ៉ុបខាងកើត។ ពួកគេបានជីកគាស់រណ្តៅនិងដុតសាកសព ព្រមទាំងបំផ្លាញជំរំមរណៈចោល ដែលបានសាងសង់ឡើងដើម្បីឲ្យងាយស្រួលលុបបំបាត់វិញ។

បន្ទាប់សង្គ្រាមលោកលើកទី២ បានបញ្ចប់ភ្លាម ការបដិសេធន៍អំពីហូឡូខស្តបានកើនឡើង ដោយឡែក គឺក្នុងចំណោមអតីតអ្នកគាំទ្រនិងអ្នកចូលរួមនៃរបបណាហ្ស៊ី និងអ្នកចូលរួមចលនាសហការនៅអឺរ៉ុប ដែលបានបដិសេធ មិនទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍។ ការបដិសេធអំពីហូឡូខស្ត គឺជាសំណុំរឿងអះអាងប្រវត្តិសាស្ត្រដែលតំណាងឲ្យរបបណាហ្ស៊ី និងដែលបានកើតឡើងដោយសារតម្រូវការនយោបាយនៃចលនាគាំទ្រមនោគមណាហ្ស៊ីថ្មី

១ http://genocidewatch.net/genocide-២/៨-stages-of-genocide/



លោក Gregory H. Stanton ជាស្ថាបនិកនៃអង្គការ
(ទទួលបានពី៖ អង្គការឃ្លាំមើលអំពើប្រល័យពូជសាសន៍)

## តើជនបដិសេធហូឡូខសត៍អះអាងយ៉ាងដូចម្តេច?

អ្នកបដិសេធហូឡូខសត៍ (ឬការជំទាស់) ត្រូវបានចាត់ទុកជាទម្រង់នៃ «ការកែតម្រូវប្រវត្តិសាស្ត្រ»[២] ដ៏ខ្លាំងបំផុត ពាក់ព័ន្ធទៅនឹងសង្គ្រាមលោកលើកទី២។ ទោះបីជាមានការទទួលស្គាល់ទូលំទូលាយថា ការបដិសេធន៍អំពីហូឡូខស្ត និងកែប្រែនិយម ជានីតិដាច់ដោយឡែកពីគ្នាក៏ដោយ ក៏ជារាយៗ ពាក្យ «ការកែតម្រូវហូឡូខសត៍» ត្រូវបានប្រើនៅក្នុងការពិភាក្សាសាធារណៈ និងកម្រិតសិក្សាផងដែរ។ ជនបដិសេធចូលចិត្តហៅខ្លួនឯងថា «អ្នកកែតម្រូវ» ក្នុងន័យចង់ធ្វើឲ្យខ្លួនជាអ្នកត្រឹមត្រូវ ពូកែសិក្សារៀនសូត្រនិងស្រាវជ្រាវ។

ពួកអ្នកបដិសេធយល់ថាហូឡូខស្តមិនដែលកើតឡើងឡើយ វាជារឿងប្រឌិតទាំងស្រុង ត្រូវបានតែងឡើងដើម្បីជាផលប្រយោជន៍របស់ប្រទេសអ៊ីស្រាអែល និងក្រុមឃុបខិតជ្វីហ្វអន្តរជាតិ។ ជនបដិសេធបន្ថយតួលេខជនរងគ្រោះ បន្ថែមលើការបដិសេធន៍អំពីវត្តមាននៃគម្រោងកំទេច និងការប្រើសាលបន្ទប់បំពុលហ្គាស់ នៅជំរំ អោស្វិច-ប៊ីខឺណៅ ដើម្បីបំពុលជនជាតិជ្វីហ្វឲ្យសម្លាប់ក្នុងចំនួនយ៉ាងច្រើនបែបនេះ។ អ្នកបដិសេធក៏បានបន្ទាបចំនួននៃការរងទុក្ខនិងការបំផ្លាញ ដោយសារគោលនយោបាយរបស់ណាហ្ស៊ីនៅអឺរ៉ុប ដោយអះអាងថាវិនាសកម្មទាំងនោះ កើតឡើងពីជំលោះប្រដាប់អាវុធនិងជំងឺតែប៉ុណ្ណោះ។ ពួកគេបដិសេធពីការបំបាត់ជនជ្វីហ្វអន្តរជាតិដោយរបបណាហ្ស៊ី និងថែមទាំងអះអាងថា ជនជាតិជ្វីហ្វភាគច្រើន ត្រូវបានអនុញ្ញាតឲ្យធ្វើនិរប្រវេស្តទៅសហរដ្ឋអាមេរិក និងថាសក្ខីកម្មរបស់អ្នកដែលនៅរស់រានមានជីវិត ត្រូវបានបំផ្លើស។ ពួកគេអះអាងថា សៀវភៅកំណត់ហេតុរបស់ អាន់ ហ្វ្រែង ជាសិប្បនិម្មិតក្លែងក្លាយ។

## ការប្រកែករបស់ពួកអ្នកបដិសេធ អាចបំបាក់ជម្នះបានយ៉ាងងាយស្រួល តាមរយៈភស្តុតាងខាងក្រោម ៖

**► ហូឡូខសត៍ត្រូវបានកត់ត្រាយ៉ាងច្បាស់ និងមានឯកសារជាច្រើនដែលកងទ័ពសម្ពន្ធមិត្តយកបាន មុនពេលពួកណាហ្ស៊ីបំផ្លាញចោល។ ឯកសារទាំងនេះ រួមមាន របាយការណ៍លម្អិតអំពីការសម្លាប់ទ្រង់ទ្រាយធំ និងការបំពុលដោយឧស្ម័ន។ ឯកសារខ្លះត្រូវបានព្រះរាជអាជ្ញាយកមកបង្ហាញនៅក្នុងតុលាការ Nuremburg។**

**► សក្ខីកម្មដើមនៃអ្នកនៅរស់ពីហូឡូខស្ត មានដូចជា ហ្វីល និងរូបថតពីការសម្លាប់ ដែលមានខ្លះត្រូវបានថតដោយលួចលាក់។ អ្នករំដោះជំរំក៏បានថតរូបនឹងភាពយន្តដែរ។**

**► ពួកណាហ្ស៊ីអាល្លឺម៉ង់ និងអ្នករួមសហការ មិនត្រឹមតែសម្លាប់ជនជាតិជ្វីហ្វដែលរស់នៅក្នុងប្រទេសអាល្លឺម៉ង់ប៉ុណ្ណោះទេ គឺរួមទាំងជ្វីហ្វដែលរស់នៅទូទាំងទ្វីបអឺរ៉ុបផងដែរ គឺមានជនជាតិជ្វីហ្វចំនួនប្រមាណប្រាំមួយលាននាក់ត្រូវបានសម្លាប់។**

**► ការសម្លាប់ជនជ្វីហ្វទ្រង់ទ្រាយធំដោយបំពុលហ្គាស់ Zyklon B ក្នុងជំរំមរណៈ បញ្ជាក់ដោយសក្ខីកម្មពីពួកជនដៃដល់ដោយខ្លួនឯង ព្រមទាំងអ្នកទោស និងសមាជិកនៃក្រុម «Sonderkommando» ដែលត្រូវបង្ខំឲ្យយកសាកសពចេញបន្ទប់បំពុលហ្គាស យកទៅបោះចោល។ ភស្តុតាង ក៏ត្រូវបានរកឃើញតាមការកំណាយនៅតាមទីកន្លែងដែលពួកណាហ្ស៊ីធ្វើជាជំរំប្រមូលផ្តុំ និងជំរំមរណៈ។**

**► អ្នកជំនាញផ្នែកកោសល្យវិច័យ និងបុរាណវិទូ ក៏បានធ្វើការស៊ើបអង្កេត ពិនិត្យកន្លែងសម្លាប់ជនជាតិជ្វីហ្វទ្រង់ទ្រាយធំនៅអឺរ៉ុបខាងកើត និងទីតាំងនៅអតីតសហភាពសូវៀត ជាកន្លែងដែលណាហ្ស៊ីអាល្លឺម៉ង់ច្រើនតែសម្លាប់ជនជាតិជ្វីហ្វនៅនឹងកន្លែង (ដោយបាញ់សម្លាប់)។ រឿងនេះក៏បានកើតឡើងនៅពេលជ្វីហ្វត្រូវដឹកបញ្ជូនទៅជំរំនៅក្នុងប្រទេសប៉ូឡូញផងដែរ។**

---

២ "Historical revisionism" គឺជាការបកស្រាយឡើងវិញអំពីទស្សនៈដែលមានស្រាប់ ទៅលើការញ៉ាំងលើកទឹកចិត្ត ភស្តុតាងនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាក់លាក់។


Irving leads death camps tour

By Natalie Pankowska for Antifa-Net in Warsaw

N. Pankowska: Iving ដឹកនាំដំណើរបោះតង់មរណៈ "Searchlight" [ចក្រភពអង់គ្លេស ខែ១១ ឆ្នាំ២០១០ បណ្ណាសារដ្ឋានរបស់ NEVER AGAIN] PDF

## ធនធានព័ត៌មានអំពីការបដិសេធន៍ហូឡូខសត៍៖

► Teachers resources "What is Holocaust Denial" by Simon Wiesenthal Center

► Prof. Deborah Lipstadt`s talk «Behind the Lies of Holocaust Denial» (video)

► The United States Holocaust Memorial Museum`s materials about Holocaust denial

► What is Holocaust denial? by the Auschwitz-Birkenau Memorial Museum

## សំណួរសម្រាប់គិតពិចារណា៖

**១) តើការបដិសេធន៍ចំពោះអំពើប្រល័យពូជសាសន៍ អាចជាផលវិបាកអ្វីខ្លះ?**

**២) តើវិធីសាស្ត្របដិសេធចម្បងរបស់អ្នកបដិសេធអំពើឃោរឃៅ/ប្រល័យពូជសាសន៍ក្នុងប្រទេសរបស់អ្នក មានវិធីតវ៉ា ប្រើយុទ្ធសាស្ត្រអ្វីខ្លះ និងធ្វើដូចម្តេចខ្លះ?**
**(ឧ.ទ អំពើឃោរឃៅប្រឆាំងនឹងរ៉ូហ៊ីយ៉ានៅក្នុងប្រទេសភូមា អំពើឃោរឃៅរបស់ខ្មែរក្រហមនៅក្នុងប្រទេសកម្ពុជា អំពើឃោរឃៅនៅប្រទេសថៃ) តើទង្វើទាំងនេះផ្តល់ផលប៉ះពាល់អ្វីខ្លះមកលើសង្គមសព្វថ្ងៃ?**

## តើការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ជាអ្វី ហើយហេតុអ្វីវាខុសពីការបដិសេធន៍?

នៅការបដិសេធន៍អំពីហូឡូខសត៍ គឺជាការបដិសេធនូវការពិតទាំងស្រុងនូវអំពើហូឡូខសត៍ដែលបានកើតឡើង។ ចំណែកការបំផ្លែងទ្រង់ទ្រាយ គឺមានភាពសាំញាំជាងនេះ និងពិបាកយល់ ឬស្គាល់។ វាគឺជាការក្រឡាបំផ្លៃ និងប៉ិនប្រសព្វបំផ្លែងការពិតនៃប្រវត្តិសាស្ត្រ។ ការវែកញែកនិងល្បិចរបស់អ្នកបំផ្លែង អាចមានលក្ខណៈផ្សេងៗគ្នានៅតាមប្រទេស អាស្រ័យលើប្រវត្តិ សង្គម នយោបាយ និងបទពិសោធន៍របស់ប្រទេសនីមួយៗ នៅអំឡុងពេល និងក្រោយពេលសង្គ្រាមលោកលើកទីII គឺថា តើវាជារដ្ឋគ្រប់គ្រងដោយជនដៃដល់? គ្រប់គ្រងដោយពួកណាហ្ស៊ី ឬសមាជិកសម្ព័ន្ធ អាក់ស៊ីស? ជារដ្ឋអព្យាក្រិត្យ ឬរដ្ឋមួយក្នុងចំណោមសម្ព័ន្ធមិត្ត?

ការលេងសើចអំពីហូឡូខសត៍គឺជាទម្រង់មួយនៃការបំផ្លែងទ្រង់ទ្រាយ។ មានន័យថាការប្រើប្រាស់ពាក្យហូឡូខសត៍ រូបសញ្ញា ដើម្បី ១) ការប្រៀបធៀបហូឡូខសត៍ណាតហ្ស៊ី ទៅនឹងព្រឹត្តិការណ៍ដែលមិនសូវធ្ងន់ធ្ងរ ឬព្រឹត្តិការដែលកើតឡើងធម្មតា ២) ការកាត់បន្ថយអ្នកតស៊ូនឹងហូឡូខសត៍ ឬអ្នកទាំងឡាយដែលបានជួយសង្គ្រោះជនជាតិជ្វីហ្វ ទៅនឹងការស្នេហាជាតិ ឬការដាក់ថាឲ្យពួកគេធ្វើក្នុងគោលបំណងមនោគម/ជាតិនិយម ៣) និយាយពិពណ៌នាបញ្ហាអាកប្បកិរិយា ឬឥរិយាបថមិនត្រឹមត្រូវណាមួយ ថាដូចទៅនឹងណាហ្ស៊ី ឬដើម្បី ៤) បន្ថយសារសំខាន់នៃហូឡូខសត៍ និងបន្ទាបពីចំណែកដ៏សំខាន់ចំពោះប្រវត្តិសាស្ត្រសកលលោក និងរបស់ជនជាតិជ្វីហ្វសម័យទំនើប។
ការប្រៀបធៀបអំពើហូឡូខសត៍ និងអំពើឃោរឃៅរបស់ណាហ្ស៊ីជាមួយនឹងជម្លោះនៅបជ្ឈិមបូព៌ា គឺជាឧទាហរណ៍មួយនៃការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍។ ជាញឹកញាប់ ការបៀបធៀបនេះ កើតឡើងដោយនិន្នាការប្រឆាំងនឹងជនជាតិជ្វីហ្វ (ការស្អប់ជនជាតិជ្វីហ្វ និងការដែលថាប្រទេសអ៊ីស្រាអែលជារដ្ឋជ្វីហ្វ) និងអាចបណ្ដាលមកពីកង្វះចំណេះដឹងអំពីហូឡូខសត៍ និងបរិបទ។ ក្នុងករណីមួយចំនួនអាចហៅថាជាការប្រៀបបញ្ច្រាស់ហូឡូខសត៍ ដែលចោទប្រកាន់ជនជាតិជ្វីហ្វជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មប្រហាក់ប្រហែលនឹង ឬធ្ងន់ធ្ងរខ្លាំងជាងហូឡូខសត៍ទៅវិញ។
ការផលិត និងលក់វត្ថុអនុស្សាវរីយ៍អំពីហូឡូខសត៍ដើម្បីចំណេញជាផលប្រយោជន៍ ក៏ជាកត្តាគ្រោះថ្នាក់មួយនៃការធ្វើអាជីវកម្ម និងមិនអើពើចំពោះស្មារតីហូឡូខសត៍ដែរ។

**សិក្សាបន្ថែមអំពីបញ្ហានេះ និងការបំផ្លែងទ្រង់ទ្រាយផ្សេងទៀត តាមរយៈ** [IHRA publication]

ខណៈដែលបញ្ហាហូឡូខសត៍នៅភាគខាងលិចត្រូវបានលើកមកពិភាក្សាច្រើន តាំងពីទសវត្សឆ្នាំ១៩៧០ បញ្ហានេះបានក្លាយជាឧបសគ្គថ្មីនៅអឺរ៉ុបកណ្ដាលនិងខាងកើត បន្ទាប់ពីប្រព័ន្ធកុម្មុយនីស្តដួលរលំ។ នៅទីនោះ ការសិក្សាស្រាវជ្រាវអំពីអតីតកាល ត្រូវបានអមដោយបក្សភាពជនរងគ្រោះ និងប្រភេទបំផ្លែងទ្រង់ទ្រាយ រាក់កំផែលផ្សេងៗនៃហូឡូខសត៍ ដែលបំពេញចន្លោះតម្រូវការក្រោយពីគ្មានការបញ្ច្រៀបអំពីអតីតកាលនៃការបរិយាប្រវត្តិសាស្ត្រជាតិ។



រូបថត៖ សាស្ត្រាចារ្យ ម៉ៃខល ស្សាហ្វីរ (Michael Shafir) គឺជាអ្នកសិក្សាឈានមុខស្តីពីការប្រឆាំងជនជាតិជ្វីហ្វ និងការប្រព្រឹត្តនៃ ហូឡូខសត៍ នៅអឺរ៉ុបកណ្ដាល និងអឺរ៉ុបខាងកើត
(ប្រភពយោងពី៖eurolibera.org)

លោកសាស្ត្រាចារ្យ ម៉ៃខល ស្សាហ្វីរ សរសេរអំពីការមានទូទៅនៃជម្រើសជំទាស់ ***"selective negationism"*** ក្នុងប្រទេសដែលបានសហការជាមួយអាល្លឺម៉ង់ អ៊ីត្លែរ (ឧ.ប្រទេសរ៉ូម៉ានី) ឬត្រូវបានកាន់កាប់ដោយណាហ្ស៊ី នៅអឺរ៉ុបកណ្ដាល និងអឺរ៉ុបខាងកើត គឺការតស៊ូមតិរបស់វា ***«មិនបដិសេធថាហូឡូខសត៍កើតឡើងនៅកន្លែងផ្សេង ប៉ុន្តែមិនរាប់បញ្ចូលដែលចូលរួមជាសមាជិករបស់ជាតិខ្លួន ឬបានបន្ទាបបន្ថយទៅកម្រិតតិចបំផុត»***។ ទម្រង់មួយទៀតដែលលោកបានកំណត់នៅក្នុងតំបន់នោះ គឺរបៀបប្រៀបធៀបរាក់កំផែល ***"comparative trivialisation"*** អំពីហូឡូខសត៍ ក្នុងគោលបំណងបង្ហាញថា ***«ហូឡូខសត៍មិនមែនជាការប្រល័យពូជសាសន៍ថ្មីក្នុងប្រវត្តិសាស្រ្ត ហើយក៏មិនមែនការសម្លាប់ធ្ងន់ធ្ងរជាងគេនៅក្នុងចំណោមអំពើឃោរឃៅនៅសតវត្សរ៍ទី២០ដែរ»***។

ក្នុងចំណោមឧទាហរណ៍ថ្មីនេះ ស្ដីអំពីការធ្វើរាក់កំផែលចំពោះហូឡូខសត៍ គឺការបៀបធៀបពីការធ្វើទុក្ខបុកម្នេញរបស់ណាហ្ស៊ីទៅលើជនជាតិជ្វីហ្វ ជាមួយវិធានការការពារទប់ស្កាត់ជំងឺកូវីត ដោយអ្នកតវ៉ាមិនចាក់វ៉ាក់សាំង និងការប្រើប្រាស់សញ្ញាហូឡូខសត៍ ដូចជា ផ្កាយដេវីតពណ៌លឿង ដែលជនជាតិជ្វីហ្វនៅអឺរ៉ុបត្រូវពួកណាហ្ស៊ីបង្ខំឲ្យពាក់ ដើម្បីបង្អាប់ពួកគេធ្វើឲ្យអាម៉ាស់មុខ។ ពួកគេហៅសញ្ញានេះថាជាសញ្ញានៃ «ការធ្វើទុក្ខបុកម្នេញ» ចំពោះអ្នកមិនចាក់វ៉ាក់សាំង នៅទូទាំងពិភពលោក។

## អនុសាសន៍សម្រាប់ការអាន៖

► **អានអត្ថបទរបស់អ្នកស្រាវជ្រាវឈានមុខអំពីហូឡូខសត៍ និងជាប្រធានកិត្តិយសនៃសម្ព័ន្ធចងចាំហូឡូខសត៍អន្តរជាតិ គឺសាស្ត្រាចារ្យ Yehuda Bauer ក្នុងអត្ថបទដែលលោកបានសរសេរពិភាក្សាពីទស្សនៃការប្រើអតីតកាល និង មុខងារគាំទ្រលទ្ធិជាតិនិយម៖ ការបង្កើតអតីតកាល «ដែលអាចប្រើប្រាស់បាន»៖ ស្តីពីការបដិសេធន៍អំពីហូឡូខសត៍និងការបំផ្លែងទ្រង់ទ្រាយ។ លោកសាស្ត្រាចារ្យ Bauer លើកឡើងអំពីលក្ខណ:ខុសប្លែកគ្នារវាងការបដិសេធន៍និងការបំផ្លែងទ្រង់ទ្រាយ ឬសគល់ប្រវត្តិសាស្ត្រនៃការបដិសេធន៍។ សាវតាចាំបាច់ដែលបណ្ដាលឲ្យកើតមានការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ គឺ«ការកើតឡើងនៃរបបអំណាចផ្ដាច់ការនិយម ប្រជានិយម ជាតិនិយម និងការប្រឆាំងសេរីនិយម ដែលបានកំពុងកើតឡើងលើពិភពលោកអស់រយ:ពេលប្រហែលពីរទសវត្សរ៍កន្លងមក»។**

► **សិក្សាបន្ថែមពីឧទាហរណ៍នៃការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ តាមរយ: Understanding Holocaust Distortion - Contexts, Influences and Examples.**

## សំណួរពិចារណា៖

**១) តើការស្ញៀមស្ងាត់ចំពោះទស្សន:ជាក់លាក់ណាមួយនៃប្រវត្តិសាស្រ្តជាតិ អាចជាទម្រង់មួយនៃការបដិសេធន៍អំពើប្រល័យពូជសាសន៍/ហូឡូខសត៍ឬទេ?**
**២) តើលក្ខណ:អ្វីខ្លះ ដែលសម្គាល់ពីភិនភាគ/ការតវ៉ានៃអ្នកបដិសេធអំពើប្រល័យពូជសាសន៍ និងហូឡូខសត៍?**
**៣) តើអ្វីទៅជាតួនាទីរបស់មនោគមជាតិនិយមនៅក្នុងការបដិសេធន៍និងបំផ្លែងទ្រង់ទ្រាយអំពើប្រល័យពូជសាសន៍?**




ឧទាហរណ៍ទី១៖ ការប្រើសញ្ញាផ្កាយលឿងដេវីត ពីសម័យហូឡូខសត៍ ដែលជនជាតិជ្វីហ្វនៅអឺរ៉ុបត្រូវណាហ្ស៊ីបង្ខំឲ្យពាក់ ដោយអ្នកប្រឆាំងតវ៉ាមិនចាក់វ៉ាក់សាំង (ប្រភព៖ ADL.org)




ឧទាហរណ៍ទី២៖ ការយកហូឡូខសត៍ធ្វើជារឿងទូទៅ
ពែងតែ មានរូប Marek Edelman ដែលជារូបសញ្ញាមួយនៃ
ការបះបោររបស់ជ្វីហ្វនៅទីក្រុងវ៉ស
(ប្រភព៖ ប័ណ្ណសារដ្ឋាន  NEVER AGAIN)

# ការបំផ្លែងទ្រង់ទ្រាយហូឡូខូស្តនៅអឺរ៉ុបខាងកើត
## *ការជជែកពិចារណាទៅលើសៀវភៅរបស់ Jan T. Gross*
## ដើមទសវត្សឆ្នាំ២០០០

តួនាទីសំខាន់មួយនៅក្នុងដំណើរការដោះស្រាយនឹងអតីតកាល និងការប្រឈមនឹងភាពបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ ត្រូវបានប្រវត្តិវិទូនិងសាស្ត្រាចារ្យជនជាតិអាមេរិកាំងប៉ូឡូញមួយរូប នៅសកលវិទ្យាល័យ ព្រីនស្តុន គឺលោក ជេន ធី ហ្គ្រូស្ស យកមកសិក្សា ហើយសៀវភៅរបស់គាត់ដែលមានចំណងជើងថា **«អ្នកជិតខាង។ ការបំផ្លិចបំផ្លាញនៃសហគមន៍ជនជាតិជ្វីហ្វនៅ Jedwabne ប្រទេសប៉ូឡូញ»** (Princeton, ២០០១) សៀវភៅ **«ការភ័យខ្លាចៈ ការប្រឆាំងជនជាតិជ្វីហ្វនៅក្នុងប្រទេសប៉ូឡូញបន្ទាប់ពីជំរំអោស្វិច»** (Random House ២០០៦) និង សៀវភៅ **"Golden Harvest: Events at the Periphery of the Holocaust"** (co-authored with Irena Grudzinska-Gross, Oxford University Press, ២០១២) ជេន ធី ហ្គ្រូស្ស បានស្រាវជ្រាវទៅលើប្រធានបទដែលមិនត្រូវបានយកចិត្តដាក់កាលពីមុនៗមក។ សៀវភៅនីមួយៗបង្ហាញពីមជ្ឈដ្ឋានជុំវិញការជជែកវែកញែកតាមវគ្គ។

នៅក្នុងសៀវភៅបោះពុម្ពលើកទី១ជាភាសាប៉ូឡូញ ក្នុងឆ្នាំ២០០០ និងឆ្នាំបន្ទាប់ ជាភសាអង់គ្លេស គឺសៀវភៅដែលមានចំណងជើងថា «អ្នកជិតខាង» លោកក្រូស្ស បានសរសេរអំពីចលនាសម្លាប់បំបាត់ជនជាតិជ្វីហ្វ ដែលកើតឡើងនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៤១ នៅ Jedwabne ជាទីក្រុងតូចមួយស្ថិតនៅភាគខាងកើតប្រទេសប៉ូឡូញ។ អ្នកភូមិជាជនជាតិប៉ូឡូញនិងអ្នកនៅជិតខាងនោះ បានចាប់ផ្តើមប្រមូលជនជាតិជ្វីហ្វនៅទីក្រុងនោះឲ្យទៅទីប្រជុំជននៅកន្លែងផ្សារ។ នៅទីនោះ ជនជាតិជ្វីហ្វត្រូវបានគេវាយដំ និងធ្វើឲ្យអាម៉ាស់ មួយចំនួនត្រូវបានគេសម្លាប់។ ក្រោយមក ជនជាតិជ្វីហ្វទាំងអស់ត្រូវដាក់នៅម្តុំផ្សារដដែលនោះ ត្រូវបញ្ជូនទៅនៅក្នុងជង្រុកតែមួយ ស្រោចដោយប្រេងប៉ារ៉ាហ្វីន និងត្រូវដុតសម្លាប់។ ជនជាតិអាល្លឺម៉ង់នៅក្នុងទីក្រុងនោះ ប៉ុន្តែមិនបានចូលរួមដោយផ្ទាល់នៅក្នុងការសម្លាប់នោះទេ។

តាមរយៈសៀវភៅរបស់លោក ប្រវត្តិវិទូរូបនេះ បានញ៉ាំងឲ្យមានការចាប់ផ្តើមពិភាក្សាជាលក្ខណៈជាតិដ៏ធំមួយ ស្តីអំពីទំនាក់ទំនងរវាងជនជាតិជ្វីហ្វនិងអ្នកជិតខាងរបស់ពួកគេដែលជាគ្រិស្តសាសនិក ការប្រឆាំងជនជាតិជ្វីហ្វ អំពើហិង្សាប្រឆាំងនឹងជនជាតិជ្វីហ្វក្នុងពេលសង្គ្រាមនៅក្នុងប្រទេសប៉ូឡូញ និងនៅប្រទេសនៅអឺរ៉ុបផ្សេងទៀតដែលណាហ្ស៊ីកាន់កាប់។ សៀវភៅនោះ បានទាញចំណាប់អារម្មណ៍ទៅលើរឿងរ៉ាវរបស់សហគមន៍សាមញ្ញមួយ ដែលស្ថិតនៅក្នុងកាលៈទេសៈនៃសង្គ្រាម ការបំផ្លិចបំផ្លាញ និងភាពឃោរឃៅ (សង្គមប៉ូឡូញខ្លួនឯងផ្ទាល់ ត្រូវបានកាន់កាប់ដោយយង់ឃ្នងដោយពួកណាហ្ស៊ីអាល្លឺម៉ង់ នៅអំឡុងពេលសង្គ្រាមលោកលើកទី២)។ នៅក្នុងអំឡុងពេលមានការជជែកពិភាក្សានេះ សង្គមប៉ូឡូញត្រូវបានបែងចែង ដោយមានទាំងប្រតិកម្មវិជ្ជមាននិងអវិជ្ជមានចំពោះសៀវភៅនេះ។






Professor Jan Tomasz Gross
(credit: Princeton University)



ការសរសេរប្រឆាំងនឹងលោក ហ្រ្គុស្ស មានរាប់រយច្បាប់ ត្រូវបានចេញផ្សាយនៅឆ្នាំបន្ទាប់មកនោះ។ អ្នកបំផ្លែងទ្រង់ទ្រាយបានចោទប្រកាន់លោក ហ្រ្គុស្ស ពីការដាក់សន្មតទូទៅ បំផ្លើសការពិត ប្រឆាំងនឹងប៉ូឡូញ និងមិនមានលក្ខណៈសិក្សារៀនសូត្រ។ ពួកគេបានបង្ហាញពីការអះអាង ជនរងគ្រោះ competitive victim បញ្ជាក់ពីការពិតនៃការរងទុក្ខរបស់ប្រជាជនប៉ូឡូញខ្លួនឯង នៅអំឡុងពេលសង្គ្រាមលោកទី២ ដោយបានបដិសេធពីការចូលរួមរបស់ជនជាតិប៉ូឡូញ នៅក្នុងអំពើហិង្សាប្រឆាំងនឹងជនជាតិជ្វីហ្វ ហើយបានផ្តោតលើតែកំហុសរបស់អាល្លឺម៉ង់នៅក្នុងការសម្លាប់រង្គាលនៅក្រុង Jedwabne (selective negation)។ នៅក្នុងអំឡុងពេលមានការជជែកពិភាក្សានេះ សង្គមប៉ូឡូញត្រូវបានបែងចែង ដោយមានទាំងប្រតិកម្មវិជ្ជមាននិងអវិជ្ជមានចំពោះការសម្លាប់បំបាត់ជនជាតិជ្វីហ្វនៅក្រុង Jedwabne (selective negation)។

ទោះបីជាយ៉ាងណា រដ្ឋាភិបាលប៉ូឡូញបានចាត់តាំងឲ្យមានការស៊ើបអង្កេតមួយ ដឹកនាំដោយវិទ្យាស្ថានជាតិចងចាំ (IPN) ដែលបានបញ្ជាក់ថាជនជាតិប៉ូឡូញបានចូលរួមក្នុងចលនាសម្លាប់បំបាត់ជនជាតិជ្វីហ្វនោះ។

អ្នកសារព័ត៌មានជនជាតិប៉ូឡូញ ឈ្មោះ អានណា ប៊ិកុន បានធ្វើការស៊ើបអង្កេតដោយខ្លួនឯង និងសម្ភាសប្រជាជននៅក្រុង Jedwabne។ ក្រោយមក នាងបានបោះពុម្ពផ្សាយសៀវភៅចំណងជើងថា My z Jedwabnego ("**Jedwabne: Battlefield of Memory**") នៅឆ្នាំ២០០៤។




បូជនីយដ្ឋាន នៅក្រុង Jedwabne (ប្រភព៖ Wikimedia Commons)






Anna Bikont (ប្រភព៖ Wikimedia Commons)

## ២០០៩/១០

ល្ខោនរឿង "**Nasza klasa/Our Class**" និយាយអំពីមិត្តរួមថ្នាក់មួយក្រុម និងអ្នកជិតខាងនៅក្រុង Jedwabne មានប៉ូឡូញ និងជ្វីហ្វ ពីឆ្នាំ១៩២៥ មកទល់ពេលបច្ចុប្បន្ន ត្រូវបាននិពន្ធដោយ Tadeusz Slobodzianek និងលេងនៅក្នុងរោងល្ខោនប៉ូឡូញ។ នេះជារឿងសម្តែងដំបូងដែលនិយាយអំពីអំពើឃោរឃៅនៅក្រុង Jedwabne ដោយញ៉ាំងពីសៀវភៅ **«អ្នកជិតខាង»** របស់ ជេន ធី ហ្រ្គូស្ស។

## ២០១២

សៀវភៅដែលមានចំណងជើងថា **«អ្នកជិតខាង»** របស់លោក ជេន ធី ហ្រ្គូស្ស បានជំរុញឲ្យមានការពិភាក្សាប្រហាក់ប្រហែលគ្នានេះ នៅតាមភូមិភាគផ្សេងៗនៅអឺរ៉ុបខាងកើត ដូចជាប្រទេសរ៉ូម៉ានី ម៉ូឡូវ៉ា ឬលីទុយអានី ទោះបីជាបរិបទប្រវត្តិសាស្រ្តរបស់ពួកគេមានភាពខុសប្លែកគ្នាក៏ដោយ។ ឧទាហរណ៍ នៅឆ្នាំ២០១២ អ្នកនិពន្ធជនជាតិម៉ូឡូវ៉ា ឈ្មោះ Nicoleta Esinencu ដែលបានរៀនសូត្រអំពីហូឡូខសត៍ នៅក្នុងប្រទេសកំណើតរបស់នាង គឺប្រទេសអាល្លឺម៉ង់ កាលពីនាងមានអាយុជាងម្ភៃឆ្នាំ បានសរសេរ និងបង្ហាញនៅក្នុងការសម្តែងរបស់នាងឈ្មោះ "**Clear History**" អំពីជនផ្តាច់ការរ៉ូម៉ានី និងសម្ព័ន្ធមិត្តរបស់អ៊ីត្លែរ Ion Antonescu និងវាសនាដ៏អណោចអធមរបស់ជនជាតិជ្វីហ្វ និងរ៉ូម៉ា ក្រោមការគ្រប់គ្រងរបស់ជនផ្តាច់ការនេះ។

ប្រវត្តិវិទូម៉ូឡូវ៉ា ឈ្មោះ Diana Dumitru ដែលបានសរសេរសៀវភៅអំពីតួនាទីរបស់អ្នកក្នុងស្រុកនៅក្នុងហូឡូខសត៍នៅប្រទេសរ៉ូម៉ានី មានចំណងជើងថា "**The State, Antisemitism, and Collaboration in the Holocaust: The Borderlands of Romania and the Soviet Union**" (២០១៨) បាននិយាយថានាងមានគំនិតសរសេរនេះ កើតចេញតាមរយៈសៀវភៅឈ្មោះ «អ្នកជិតខាង» របស់ ជេន ធី ហ្រ្គូស្ស។



កូនសិស្សសាលាប៉ូឡូញ (ជ្វីហ្វ និងគ្រិស្តសាសនិក) ថតជាមួយគ្រូបង្រៀនរបស់ពួកគេ នៅក្រុង Jedwabne ប្រទេសប៉ូឡូញ ឆ្នាំ១៩៣៣។
(ប្រភព៖ Wikimedia Commons, source: Jewish Historical Institute)







ប្រភព៖ បណ្ណសារដ្ឋាន ល្ខោន "Spalatorie", Chisinau, ប្រភម៉ូឡូវ៉ា

នៅប្រទេសលីទុយអានី មានអ្នកប្រមាញ់ពួកណាហ្ស៊ីដ៏ល្បីម្នាក់ និងជាកូនចៅជំនាន់ក្រោយរបស់អ្នករងគ្រោះហូឡូខសត៍ ឈ្មោះ Efraim Zuroff និងអ្នកនិពន្ធឈ្មោះ Ruta Vanagaite ជាអ្នកជំនាន់ក្រោយរបស់អ្នកសហការជាមួយណាហ្ស៊ី បានរួមគ្នាស្រាវជ្រាវ និងបោះផ្សាយសៀវភៅមួយ មានចំណងជើងថា **«ប្រជាជនរបស់យើង។ ការរកឃើញពីអាថ៌កំបាំងហូឡូខសត៍របស់ប្រទេសលីទុយអានី»** បាននិយាយអំពីតួនាទីរបស់អ្នកក្នុងភូមិស្រុក នៅពេលមានការសម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វ និងបានសរសេរថា មន្ត្រីលីទុយអានី បានព្យាយាមលាក់បាំងពីការរួមគំនិតចូលដៃរបស់អ្នកនៅក្នុងភូមិជាមួយនោះ។

នៅក្នុងសៀវភៅទី២ ចំណងជើងថា "Fear. Anti-Semitism in Poland Shortly After the War" លោក ហ្គ្រូស្ស បានសរសេរឲ្យដឹងពីការសម្លាប់ដ៏ឃោរឃៅមួយទៀត ដែលកើតឡើងនៅក្រុង Kielce ប្រទេសប៉ូឡូញ មួយឆ្នាំក្រោយសង្គ្រាម។ មានប្រជាជនប៉ូឡូញដែលជាជ្វីហ្វតែ១០ភាគរយប៉ុណ្ណោះ ដែលបាននៅរស់រានមានជីវិតពីហូឡូខសត៍ ហើយពួកគេបានចាប់ផ្តើមត្រឡប់មកផ្ទះសម្បែងរបស់ពួកគេវិញ ដែលភាគច្រើនត្រូវបានជនជាតិប៉ូឡូញយកកាន់កាប់ទៅហើយ។ ប្រជាជនជ្វីហ្វត្រូវបានចោទប្រកាន់ពីការធ្វើពិធីបូជាឈាមដោយសម្លាប់ក្មេងប្រុស (blood libe៣l) អ្នកខ្លះត្រូវបានវាយសម្លាប់ ហើយអ្នកផ្សេងទៀត បានសម្រេចចិត្តចាកចេញពីប្រទេសប៉ូឡូញជារៀងរហូត។ សៀវភៅនេះបានលើកពីបញ្ហាកំណត់គំរូតួយ៉ាង ការប្រឆាំងជនជាតិជ្វីហ្វ និងភាពឃោរឃៅក្រោយសង្គ្រាម។

***សិក្សាបន្ថែមអំពីការសម្លាប់បំបាត់ពូជនៅ Kielce ៖ The USHMM about the Kielce pogrom***

## ២០១៧

នៅក្នុងឆ្នាំ២០១៧ សមាគម NEVER AGAIN រួមសហការជាមួយដៃគូ បានបកប្រែ និងបោះពុម្ពសៀវភៅ "Golden Harvest: Events at the Periphery of the Holocaust" (២០១១) របស់ ជេន ធី ហ្គ្រូស្ស ជាភាសាសូវៀត និងជាភាសារ៉ូមានី (ដោយផ្នែក)។ សៀវភៅនេះ
***ការប្រឆាំងនឹងជនជាតិជ្វីហ្វ និងភាពលោភលន់ ។ អានបន្ថែម ៖ NEVER AGAIN support Holocaust awareness in Eastern Europe.***
សៀវភៅដែលបានបកប្រែ ត្រូវបានសម្ភោធនៅម៉ូឡដាវ៉ា ក្នុងគោលបំណងជំរុញទឹកចិត្តសាធារណជនម៉ូឡដាវ៉ាឲ្យមានការពិចារណាពិភាក្សាអំពីប្រវត្តិសាស្ត្ររបស់ខ្លួន។

៣ សូមសន្ទានុក្រម









Jan T. Gross ប្រភពកំពុងចែករំលែកបទពិសោធន៍ស្តីពីការតស៊ូមតិប៉ូឡូញ និងនិស្សិតម៉ូឡដាវ៉ា និងសង្គមស៊ីវិលៈ Chisinau, ២០១៧. កម្មវិធីជាច្រើនបានរៀបចំដោយសមាគម NEVER AGAIN ជាមួយការគាំទ្រពី Friedrich Ebert Stiftung ម៉ូឡដាវ៉ា (ប្រភព៖ សមាគម NEVER AGAIN)




Nicoleta Esinencu is a Moldovan playwright and theatre founder and director (Credit: Spalatorie)






*ស្តាប់ការបង្រៀនរបស់ ជេន ធី ហ្គ្រូស្ស នៅសកលវិទ្យាល័យ (ជាភាសាអង់គ្លេស)៖ Lecture of Jan T. Gross at Moldova State University (with introduction of Rafal Pankowski),*

មើលបទបង្ហាញរបស់ ជេន ធី ហ្គ្រូស្ស នៅសន្និសិទ្ធរៀបចំដោយ សារមន្ទីរ ***Liberation War Museum** (ប្រទេសបង់ក្លាដេស) និងសមាគម **NEVER AGAIN:***

## ហេតុអ្វីការជជែកវែកញែកអំពីសៀវភៅរបស់ ហ្គ្រូស្ស មានសារសំខាន់?

- ការជជែកវែកញែកនោះ បានបង្ហាញពីសំណុំស្មុគស្មាញនៃហូឡូខសត៍ ដែលអាល្លឺម៉ង់បានបញ្ជ្រាបចូលដល់ដីប៉ូឡូញ នៅពេលប្រជាជនប៉ូឡូញមានឥរិយាបថផ្សេងៗគ្នា ចំពោះវាសនារបស់ជនជាតិជ្វីហ្វ គឺមានពីការអាណិតមេត្តា ទៅការព្រងើយមិនអើពើ រហូតដល់មានទាំងការស្អប់។
- បាននិយាយអំពីការផ្លាស់ប្តូរទស្សនៈយល់ឃើញអំពីសង្គ្រាមរបស់ប៉ូឡូញ និងតម្រូវការសង្គម ដែលត្រូវចងចាំអំពីហូឡូខសត៍ ដោយពិនិត្យទស្សនៈជនអ្នករងគ្រោះ។
- បានជួយនាំឲ្យការផ្សះផ្សារវាងជនជាតិប៉ូឡូញនិងជ្វីហ្វ នៅក្នុងប្រទេសប៉ូឡូញក្រោយពេលរបបកុម្មុយនីស្ត។ ប្រជាជនប៉ូឡូញ បានចាប់ផ្តើមពិនិត្យមើលដោយល្អិតល្អន់ទៅលើទស្សនៈមួយចំនួនទាក់ទងនឹងអតីតកាល និងអត្តសញ្ញាណរបស់ខ្លួន។
- បានបង្កើតការចាប់អារម្មណ៍ និងអ្នកផ្តួចផ្តើមដឹកនាំកសាងពហុនិយម និងសង្គមប្រកបដោយស្មារតីមានមនសិការ ក្នុងប្រទេសប៉ូឡូញ។

## សំណួរពិចារណា៖

១) តើទំនាក់ទំនងមនុស្សផ្លាស់ប្តូររបៀបណា នៅពេលសង្គ្រាម ហើយតើមានផលប៉ះពាល់អ្វីខ្លះទៅលើជនជាតិភាគតិច?
២) តើការស្រាវជ្រាវថ្មីអាចជួយក្នុងដំណើរការប្រឈមនឹងអតីតកាលបានយ៉ាងណា និងចូលរួមចំណែកក្នុងការជជែកវែកញែករបៀបណា? អ្វីទៅដែលអាចជាការប្រឈម?
៣) តើការជជែវែកញែកដូចនេះ មានន័យដូចម្តេចនៅក្នុងប្រទេសកម្ពុជា ប្រទេសភូមា និងប្រទេសថៃ ដែលមានប្រជាជនចម្រុះផ្សេងៗគ្នា ហើយដែលមាន «អ្នកជិតខាង» ជាច្រើនផងនោះ?
៤) តើការជជែកវែកញែកបែបនេះ អាចឆ្លើយតបតនឹងការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ និងអំពើឃោរឃៅផ្សេងៗទៀតបានឬទេ?



នៅក្នុងរូប៖ Natalia Caraion ជាគ្រូប្រវត្តិសាស្ត្រម៉ូឡូវ៉ា មកពីភូមិ កំពុងប្រគល់ផ្កាឲ្យទៅសាស្ត្រាចារ្យ ហ្គ្រូស្ស អំឡុងពេលការធ្វើបទបង្ហាញអំពីសៀវភៅរបស់លោក។ (ប្រភព៖ សមាគម NEVER AGAIN)

## តើអាចប្រៀបធៀបហូឡូខសត៍បានទេ? តើយើងអាចជៀសវាងការមិនអើពើចំពោះជនរងគ្រោះ ការចាត់ទុកជារឿងតូចតាច ធ្វើជាឧបករណ៍ ក្នុងការប្រៀបធៀបដោយរបៀបណា?

ជាញឹកញាប់ ហូឡូខសត៍ ត្រូវបានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍គំរូ ដែលអាចជួយគ្រូបង្រៀន និងកូនសិស្ស ឲ្យយល់ពីអំពើប្រល័យពូជសាសន៍ និងអំពើសាហាវឃោរឃៅផ្សេងទៀត។ វាត្រូវបានប្រើជាចំណុចចាប់ផ្តើមដើម្បីពិភាក្សាអំពីការរំលោភបំពានសិទ្ធិមនុស្ស ឬបញ្ហាប្រកាន់ផ្សេងៗក្នុងសម័យបច្ចុប្បន្ន។ អ្នកសិក្សាស្រាវជ្រាវឈានមុខមួយរូប ជាសាស្ត្រាចារ្យ Yehuda Bauer បានវែកញែកថាហូឡូខសត៍គឺជាព្រឹត្តិការណ៍ដោយឡែកមិនអាចប្រៀបមួយ និងមិនមានពីមុនមក ទោះបីជាវាមានលក្ខណៈដូចគ្នាខ្លះទៅនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដទៃ ដូចជា «អំណាចមជ្ឈិមប្រល័យពូជសាសន៍ អំណាចឃោឌា ស្ថានភាពសង្គ្រាម និងការធ្វើប្រយោជន៍សេដ្ឋកិច្ចពីទាសករជាជនជាតិជ្វីហ្វ នៅមុនពេលធ្វើឲ្យពួកគេវិសាសសាបសូន្យ»។ សាស្ត្រាចារ្យ Bauer ពន្យល់ពីមូលហេតុ៖

- **ជាលើកទី១ហើយដែលរោងចក្រទាំងនោះ ត្រូវបានសាងសង់ឡើងដើម្បីផលិតសាកសព ក្នុងករណីហូឡូខសត៍ ហើយមិនដែលមានរោងចក្របែបនេះពីមុនមកឡើយ។ គោលដៅរបស់រោងចក្រទាំងនោះគឺសម្លាប់ជនជាតិជ្វីហ្វ។**
- **ហើយពួកណាហ្ស៊ីក៏មានគោលបំណងសម្លាប់ជ្វីហ្វគ្រប់រូបនៅទូទាំងសកលលោក។**
- **វាជាលើកដំបូងបង្អស់ដែលអំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តឡើងដោយសារតែទស្សនៈមនោគម។ មនោគមវិជ្ជាដែលជំរុញឲ្យសម្លាប់ជនជាតិជ្វីហ្វដោយមិនសមហេតុផល។ វាមិនមែនដោយសារតែហេតុផលសេដ្ឋកិច្ចឡើយ។**

សាស្ត្រាចារ្យ Bauer បាននិយាយទៀតថា ហូឡូខសត៍ជាអំពើប្រល័យពូជសាសន៍មួយ ត្រូវតែប្រៀបធៀបជាមួយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផ្សេងទៀត ហើយគ្រប់គ្នាគួរតែបារម្ភពីវិសាលភាពសកលនៃទំហំប្រៀបធៀប។
ប្រសិនបើគ្មានការប្រៀបធៀប នោះពុំមានការយល់ដឹងពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដទៃទៀតឡើយ។ ការប្រៀបធៀបអាចជួយឲ្យស្គាល់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផ្សេងទៀតដែលមិនទាន់ដឹង ឧទាហរណ៍ ការប្រល័យពូជសាសន៍ទៅលើពួករ៉ូហ៊ីងយ៉ា ឬការប្រល័យពូជសាសន៍បង់ក្លាដេស នៅឆ្នាំ១៩៧១។

វាក៏មានសារសំខាន់ក្នុងការយល់ដឹងថា ឧក្រិដ្ឋកម្មមិនមែនកើតឡើងតែចំពោះ «យើង»នោះទេ។ ទស្សនៈគួរឲ្យយល់បាន ចំពោះអ្នករងគ្រោះដោយអំពើប្រល័យពូជសាសន៍យល់ថាបទពិសោធន៍របស់ពួកគេខុសប្លែកពីអ្នកដទៃ។ អ្នករងគ្រោះដោយអំពើប្រល័យពូជសាសន៍ មិនមែនជាក្រុមមហាជនអានាមិក ប៉ុន្តែជាបុគ្គលិកដែលមានរឿងរ៉ាវរបស់ពួកគេម្នាក់ៗរៀងខ្លួន។
ទោះជាយ៉ាងណា ការប្រៀបធៀបអាចជាគ្រោះថ្នាក់ នៅពេលដែលការប្រៀបធៀបពីទំហំនៃភាពរងទុក្ខ ឬចំនួនអ្នករងគ្រោះ ក្នុងគោលបំណងបង្ហាញពីកម្រិតនៃការឈឺចាប់ (ការប្រជែងពីសេចក្តីទុក្ខ)។ តួលេខមិនគួរជាចំណុចចម្បងសម្រាប់បញ្ជាក់ក្នុងឧក្រិដ្ឋកម្មឡើយ។

Konstanty Gebert ជាបញ្ញវន្តជនជាតិជ្វីហ្វប៉ូឡូញ និយាយថា អំពើប្រល័យពូជសាសន៍នីមួយៗ មានឈ្មោះដែលបង្ហាញពីលក្ខណៈខុសៗគ្នារបស់វា។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាហេតុការណ៍ផ្សេងៗគ្នា និងមានលក្ខណៈខុសប្លែកពីគ្នា ឧទាហរណ៍ Shoah គឺជាឈ្មោះសម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជ្វីហ្វ ហើយ Parajamos ជាឈ្មោះនៃការប្រល័យពូជសាសន៍ពួករ៉ូម៉ា[៤]។

---

៤ See Glossary



សាស្ត្រាចារ្យ Yehuda Bauerគឺជាអ្នកជំនាញហូឡូខសត៍ និងជាប្រធានកិត្តិយសរបស់អង្គការ IHRA (ប្រភព៖.Yad Vashem)

## មើលការបង្រៀនរបស់

- **Konstanty Gebert** រៀបចំដោយសហគម **Never Again** (ជាភាសាអង់គ្លេស)៖ [The Holocaust and Other Genocides. Is Comparison Possible?]
- សិក្សាបន្ថែមអំពីហូឡូខសត៍ និងអំពើប្រល័យពូជសាសន៍ផ្សេងទៀត៖ https://www.holocaustremembrance.com/resources/educational-materials/holocaust-and-other-genocides
- សិក្សាពីលទ្ធផលនៃការស្ទាបស្ទង់មតិ ដើម្បីដឹងពីវិធីសាស្ត្រអនុវត្តការបង្រៀនពីហូឡូខសត៍នៃស្ថាប័នផ្សេងៗ នៅក្នុងការងារទាក់ទងនឹងអំពើប្រល័យពូជសាសន៍ និងអំពើឃោរឃៅ៖ A Matter of Comparison: The Holocaust, Genocides and Crimes against Humanity

## សំណួរសម្រាប់គិតពិចារណា៖

**១) ហេតុអ្វីយើងចាំបាច់ប្រៀបធៀបហូឡូខសត៍និងអំពើប្រល័យពូជសាសន៍ផ្សេងទៀត?**
**២) ហេតុអ្វីបានជាអំពើប្រល័យពូជសាសន៍នីមួយៗមានលក្ខណៈខុសគ្នា?**

## តើយើងអាចទប់ទល់នឹងអ្នកបដិសេធហូឡូខសត៍ដោយវិធីណា?

នៅប្រទេសជាច្រើនដែលនៅក្នុងទ្វីបអឺរ៉ុប មានច្បាប់ហាមឃាត់ពីបដិសេធនូវហូឡូខសត៍ ហើយក៏មានប្រទេសជាច្រើនទៀត បង្កើតច្បាប់និតិកម្មប្រឆាំងនឹងការប្រកាន់ពូជសាសន៍រហូតដល់ការហាមប្រាមចំពោះការស្អប់ជាតិពន្ធ។  ទន្ទឹមនឹងការបដិសេធន៍ច្បាស់លាស់អំពីហូឡូខសត៍ អាចងាយស្រួលនឹងផ្តន្ទាទោស ការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ និងការធ្វើឲ្យរាក់កំផែល គឺជាកត្តាប្រឈមខ្លាំង ដោយសារតែត្រូវស្គាល់ពីទម្រង់ច្រើនបែបរបស់វាជាមុនសិន។ ម្យ៉ាងទៀត វាត្រូវបង្ហាញចេញតាមវិធីដែលមិនអាចឲ្យច្បាប់ដាក់ទោសបាន ឬដោយវិធានការប្រហាក់ប្រហែល។ វាមានការទាក់ទាមដោយឡែកសម្រាប់នៅអឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើត ដែលសង្គមកំពុងប្រឈមនឹងបញ្ហាពីអតីតកាលរបស់ពួកគេ និងស្វែងរកការបញ្ចេញបង្ហាញថ្មី ស្តីអំពីការចងចាំរួមរបស់ជាតិ។ ការជជែកតវ៉ាអំពីការសើរើកែប្រែហូឡូខសត៍ «ជួយ» ពួកគេឲ្យទទួលអារម្មណ៍នៃកំហុសតាមតួនាទីផ្សេងៗគ្នារបស់ពួកគេ ដែលមាននៅអំឡុងពេលហូឡូខសត៍។ មានប្រការគ្រោះថ្នាក់មួយ គឺថានីតិដើមដំបូងស្តីពីការបដិសេធហូឡូខសត៍ ដែលការពារការប្រើប្រាស់ខុសនូវប្រវត្តិសាស្ត្រពិត កំពុងត្រូវរដ្ឋាភិបាលធ្វើវិសោធនកម្មសរសេរឡើងវិញ ដើម្បីការពារប្រទេសជាតិទាក់ទងនឹងរឿងរ៉ាវហូឡូខសត៍[៥]។

ការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ អាចរកឃើញតាមរយៈការជជែកវែកញែកស៊ីជម្រៅ ដូចជាការវែកញែកទៅលើសៀវភៅរបស់ ជេន ជីហ្រូស្ស ដែលបានបង្កើតនូវការគិតពិចារណា ព្រមទាំងគាំទ្រការស្រាវជ្រាវអំពីហូឡូខសត៍ និងអ្នកស្រាវជ្រាវនៅកន្លែងដែលហេតុការណ៍បានកើតឡើង និងការស៊ើបអង្កេតពីបញ្ហាពីមុនដែលមិនបានយកចិត្តទុកដាក់។ ការអប់រំ និងយុទ្ធនាការបង្កើនការយល់ដឹង ស្រដៀងនឹងសកម្មភាពដែលសហគម NEVER AGAIN បានធ្វើនោះក៏មានសារសំខាន់ផងដែរ។

***សិក្សាបន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងទប់ទល់នឹងការដិសេធន៍ និងការបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ នៅលើគេហទំព័ររបស់អង្គការ IHRA ៖ [https://www.holocaustremembrance.com/task -force -against -holocaust -denial -and -distortion](https://www.holocaustremembrance.com/task-force-against-holocaust-denial-and-distortion)***



សាស្ត្រាចារ្យ Deborah Leipstadt សាស្ត្រាចារ្យ Dorot នៃប្រវត្តិសាស្ត្រជ្វីហ្វទំនើប និងការសិក្សាហូឡូខសត៍ នៅក្នុងវិទ្យាស្ថាន Emory`s Tam ដើម្បីសិក្សាពីជ្វីហ្វ និងនាយកដ្ឋានផ្នែកសាសនា និងអ្នកប្រាជ្ញនៃហូឡូខសត៍ និងការប្រឆាំងជនជាតិជ្វីហ្វសម័យទំនើប (ប្រភព៖ Wikipedia Commons)(Credit: Wikimedia Commons)

5 https://www.holocaustremembrance.com/news-archive/holocaust-denial-laws-effective-tool-or-trojan-horse, retrieved on 17.01.2022.

## IRVING TRIAL

នៅឆ្នាំ១៩៩៨ អ្នកបដិសេធហូឡូខសត៍ដែលគេស្គាល់ច្រើន ឈ្មោះ David Irving បានប្តឹងអ្នកសិក្សាជនជាតិអាមេរិក ឈ្មោះ Deborah Lipstadt និងរោងពុម្ព Penguin ដោយអះអាងថា ពួកគេបង្ខូចកេរ្តិ៍ឈ្មោះរបស់គាត់ នៅក្នុងសៀវភៅ "**Denying the Holocaust**"។ លោកបានប្រើច្បាប់បង្ខូចកេរ្តិ៍ឈ្មោះរបស់ប្រទេសអង់គ្លេស យកមកប្តឹងពីបទធ្វើឲ្យអាប់ឱនកិត្តិយស។ នៅក្នុងសៀវភៅរបស់ Lipstadt បានចោទប្រកាន់ Irving ពីការបង្ហាញភស្តុតាងខុស និងបានសរសេរថា «អ្នកនាំពាក្យដ៏គ្រោះថ្នាក់បំផុតចំពោះការបដិសេធន៍ហូឡូខសត៍»។ នាងក៏បានចង្អុលបង្ហាញពីការទាក់ទងរបស់លោកជាមួយនឹងអង្គការ និងអ្នកនិយមលទ្ធិណាហ្ស៊ីថ្មី។ គោលដៅរបស់ David Irving គឺបំបិទការរិះគន់ និងផ្សព្វផ្សាយជាសាធារណៈពីគំនិតរបស់ខ្លួន តាមរយៈតុលាការ។ អ្នកបដិសេធហូឡូខសត៍ប្តឹងតវ៉ាដល់បញ្ហាសេរីភាពក្នុងការនិយាយស្តី ក្នុងករណីដែលបដិសេធមិនបង្ហាញ និងពិភាក្សាពីគំនិតរបស់ពួកគេ នៅលើជំហរដូចគ្នានឹងអ្នកដទៃ។ តាមសេចក្តីសម្រេចដែលចេញជាលទ្ធផល គឺស្នាដៃការងាររបស់ Lipstadt និងអ្នកប្រវត្តិសាស្ត្រផ្សេងទៀត ធ្វើឲ្យបណ្តឹងរបស់ Irving ត្រូវបានច្រានចោល។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៥ David Irving ត្រូវបានចាប់ខ្លួន នៅពេលគាត់ទៅបង្រៀនក្រុមនិស្សិតនិយមស្តាំជ្រុល នៅប្រទេសអូទ្រីស។ លោកត្រូវបានចោទប្រកាន់ពីបទបដិសេធថាមិនមានបន្ទប់ឧស្ម័ន នៅជំរំ Auschwitz នៅក្នុងសេចក្តីរបស់លោក និងបទសម្ភាសន៍នៅប្រទេសអូទ្រីសក្នុងឆ្នាំ១៩៨៩។ គាត់បានជាប់ពន្ធនាគារនៅទីនោះរយៈពេលមួយឆ្នាំ មុននឹងទទួលបានការដោះលែង។

***មើលភាពយន្តជីវប្រវត្តិ ឆ្នាំ២០១៦ មានចំណងជើងថា «បដិសេធ» ដែលដឹកនាំដោយ Mick Jackson និងនិពន្ធដោយ David Hare ផ្អែកតាមសៀវភៅរបស់ Deborah Lipstadt ឆ្នាំ២០០៥ ដែលមានចំណងជើងថា «History on Trial: My Day in Court with a Holocaust Denier"។ សៀវភៅនេះ សរសេរពីករណី Irving និង Penguin Books Ltd ដែលក្នុងនោះ Lipstadt ជាអ្នកសិក្សាពីហូឡូខសត៍ត្រូវបានអ្នកបដិសេធហូឡូខសត៍ ឈ្មោះ David Irving ប្តឹងពីបទបង្ខូចកេរ្តិ៍ឈ្មោះ៖ https://bleeckerstreetmedia.com/denial***



រូបថត៖ David Irving នៅតុលាការកាត់ទោស នៅទីក្រុង វីយែន ឆ្នាំ២០០៦។
(Wikimedia Commons)




### សំណួរសម្រាប់ពិចារណា៖

**១) តើនៅក្នុងប្រទេសរបស់អ្នក អ្នកមានដឹងពីឧទាហរណ៍នៃការប្រឈមនឹងការបដិសេធន៍ និងការបំផ្លែងទ្រង់ទ្រាយនៃបទឧក្រិដ្ឋឃោរឃៅឬទេ?**
**២) តើបញ្ហាប្រឈមចម្បងក្នុងការទប់ទល់នឹងការបដិសេធន៍មានអ្វីខ្លះ ហើយអាចដោះស្រាយតាមវិធីណា?**
**៣) តើវិធីដោះស្រាយរបស់អ្នកមួយណាដែលអ្នកនឹងប្រើក្នុងការប្រឈមនឹងការបដិសេធន៍ និងការបំផ្លែងទ្រង់ទ្រាយ?**



# Opening shot

## DAVID IRVING MET WITH OUTRAGE IN POLAND

DAVID IRVING, the Holocaust revisionist writer, claimed he was surprised by the outraged reaction in Poland to the tour of Holocaust and Nazi sites he led last month.

The trip, for which enthusiasts from Britain, Germany, Australia and America paid £1,500 each excluding flights, was billed as an opportunity to experience "real history".

However officials at the former Treblinka extermination camp said they would not let Irving enter. And the director of the State Museum at Auschwitz said Irving cannot lead a tour group there because he is not a licensed guide.

Poland's Chief Rabbi Michael Schudrich said: "Mr Irving is not a historian but a charlatan and a vicious liar". Dr Rafal Pankowski, of the Never Again Association, which campaigns against racism and antisemitism and has a close relationship with Searchlight, described Irving's presence in Poland as "unacceptable and offensive to the memory of the victims" of the war.

Irving claimed the Polish people should be grateful for his visit as he was "setting the record straight". He now claims to accept that Treblinka was a "real death camp", but still denigrates Auschwitz as a reconstructed "tourist attraction".

He went on to describe people who branded him a Holocaust denier as "criminal, lying lunatics". That would presumably include Mr Justice Gray who, ruling against Irving in his libel action against the American academic Deborah Lipstadt, described him as an "active Holocaust denier", an antisemite and racist who "associates with right-wing extremists who promote neo-Nazism" and who "for his own ideological reasons persistently and deliberately misrepresented and manipulated historical evidence".

It would also include the Austrian judges who imprisoned Irving in 2006 for denying the Holocaust and "glorifying and identifying with the German Nazi Party".

David Irving met with outrage in Poland. "Searchlight", ๑๐.๒๐๑๐
Irving Leads Death Camp Tours

# តារាងអង្គហេតុប្រទេស (ជីវប្រវត្តិសង្ខេប)

# ប្រទេសកម្ពុជា



នៅក្នុងឆ្នាំ២០១៥ បូជនីយដ្ឋានមួយបានសាងសង់ឡើងដើម្បីរំឭកការចងចាំចំពោះអ្នករងគ្រោះ ដែលត្រូវស្លាប់នៅមន្ទីរសន្តិសុខ ស-២១។
(Credit: NEVER AGAIN Association, Wikimedia Commons)

## ១) ប្រវត្តិសង្ខេប និងបរិបទ

### ហេតុការណ៍ពិតជាមូលដ្ឋានអំពីប្រវត្តិសាស្ត្រសម័យទំនើប និងករណីចម្បងនៃអំពើហិង្សាទ្រង់ទ្រាយធំ

ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩៖ របបខ្មែរក្រហម និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា៖ ការធ្វើទុក្ខបុកម្នេញ និងសម្លាប់ជនជាតិភាគតិចខ្មែរ វៀតណាម ចាម(មូស្លីម) ជនជាតិភាគតិចផ្សេងទៀត និងជនបរទេស។

រយៈពេលប្រាំឆ្នាំបន្ទាប់ពីសង្គ្រាមស៊ីវិល គឺនៅក្នុងខែមេសា ឆ្នាំ១៩៧៥ ចលនាខ្មែរក្រហមដឹកនាំដោយ ប៉ុល ពត បានកាន់អំណាចនៅប្រទេសកម្ពុជា និងបានបង្កើតរបបផ្តាច់ការហៅថាកម្ពុជាប្រជាធិបតេយ្យ។ ក្នុងរយៈពេលខ្លី ពួកខ្មែរក្រហមបានបំបាត់កម្មសិទ្ធិឯកជន ទីផ្សារ វប្បធម៌ និងវិទ្យាស្ថានអប់រំ និងនយោបាយ ហើយបានបង្ខំប្រជាជននៅក្នុងទីក្រុងឲ្យទៅធ្វើការងារកសិកម្មក្នុងលក្ខខណ្ឌដ៏ពិបាកយ៉ាប់យឺនបំផុត។ របបពិឃាតបានជម្លៀសបញ្ជូនប្រជាជន៖ ការផ្លាស់ទីទ្រង់ទ្រាយធំ និងឆាប់រហ័ស ពីទីក្រុង និងទីប្រជុំជនទៅកាន់ទីជនបទ។ អំឡុងពេលដំណាក់កាលទីមួយនៃអំពើប្រល័យពូជសាសន៍ ខ្មែរក្រហមបានបែងចែកនិងចំណាត់ថ្នាក់សង្គមទៅជា «ពួកគេ» និង «ពួកយើង»។ ខ្មែរក្រហមបានបង្កើតជំនឿនៃខ្មាំងខាងក្នុង និងខ្មាំងខាងក្រៅ ដែលត្រូវមានដូចជា ភាពមិនបរិសុទ្ធ ខុសគ្នា និងបរទេស និងអ្នកដែលត្រូវចោទប្រកាន់ថាក្បត់ និងគំរាមកំហែងដល់«អង្គការ»។ តាមរយៈការដាក់បែងចែកក្នុងសង្គម ខ្មែរក្រហមក៏បានបំផ្លាញរាល់ចំណងសាមគ្គីភាពក្នុងចំណោមប្រជាជន បង្កើតបរិយាកាសពោរពេញដោយភាពភ័យខ្លាច និងការសង្ស័យ។

ក្នុងរយៈពេលដ៏ខ្លី ប្រជាជនជិតពីរលាននាក់ត្រូវស្លាប់បាត់បង់ជីវិត ដោយសារធ្វើការងារធ្ងន់ កេងប្រវ័ញ្ច ការអត់អាហារ និងនៅកន្លែងកំទេច ដូចជា មន្ទីរសន្តិសុខ ស-២១ (បច្ចុប្បន្ន សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (Tuol Sleng Genocide Museum) ព្រមទាំងទីតាំងផ្សេងទៀត នៅវាលពិឃាដ។

សូមមើល៖ Chronology of key events



### សំណួរសម្រាប់ត្រិះរិះពិចារណា៖

១) តើលក្ខណៈទ្រង់ទ្រាយចម្បងនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ជាអ្វីខ្លះ?

២) តើអំពើប្រល័យពូជសាសន៍នៅកម្ពុជាត្រូវបានដឹងឮ និងទទួលស្គាល់ជាអន្តរជាតិឬទេ?



## ការសរសេរប្រវត្តិសាស្ត្រ៖ គោលគំនិត និងធាតុសំខាន់ៗនៃការរំឭកចង់ចាំ

នៅក្រោយពេលរបបប្រល័យពូជសាសន៍ ប្រទេសកម្ពុជាបានប្រែក្លាយអតីតទីតាំងបំផ្លិចបំផ្លាញ ដូចជាមន្ទីរសន្តិសុខ ស-២១ (បច្ចុប្បន្នសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង) និងវាលពិឃាតនៅជើងឯក ទៅជាទីកន្លែងរំឭកការចងចាំរួមក្នុងប្រទេស។ ទួលស្លែង និងវាលពិឃាតជើងឯក ជាភស្តុតាងសក្ខីកម្មដ៏ពិសេសមួយ។
ទោះបីជាកំណត់ហេតុស្វ័យជីវប្រវត្តិរបស់លោក ប៉ាន់ រិទ្ធី ដែលមានចំណងជើងថា **«ការលុបបំបាត់»** (The Elimination) បានផ្តោតលើរស់រានមានជីវិតពីស្ថានភាពដ៏អាក្រក់ហួសនិស្ស័យក្រោមរបបខ្មែរក្រហម សៀវភៅនេះ បានបង្ហាញនូវសារសំខាន់ជាសកលពីការរងទុក្ខរបស់ប្រជាជនកម្ពុជា។ ភាពយន្តឯកសាររបស់លោក ស្តីពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា រួមមាន **ស-២១៖ ម៉ាស៊ីនពិឃាតរបស់ខ្មែរក្រហម និង មនុស្សបាយ** (**S-២១: The Khmer Rouge Killing Machine and Rice People**) គឺជាភាពយន្តកម្ពុជាដំបូងដែលត្រូវបានជ្រើសតាំងឈរឈ្មោះសម្រាប់ពានរង្វាន់ អូស្កា (Oscar)។ ខ្សែភាពយន្តនៅក្នុងនេតហ្វ្លិក (Netflix) របស់តារាភាពយន្តហូលីវូត និងជាសកម្មជនសិទ្ធិមនុស្ស អេនចេល្លីណា ចូលី ដែលមានចំណងជើងថា **មុនដំបូងខ្មែរក្រហមសម្លាប់ប៉ាខ្ញុំ** ត្រូវបានផ្អែកលើសក្ខីកម្មភស្តុតាងរបស់ លឿង អ៊ុង ដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម នៅពេលមានអាយុចន្លោះពីប្រាំឆ្នាំទៅ១០ឆ្នាំ។ ភាពយន្តនេះបាននាំយកសាច់រឿងរបស់ខ្មែរក្រហម និងរបបពិឃាតរបស់វា ទៅបង្ហាញដល់ទស្សនិកជនទូទាំងសកលលោក។

មានទីតាំងបូជនីយដ្ឋានជិត៨០កន្លែងត្រូវបានសាងសង់ឡើង។ រណ្តៅសាកសពជាង២០.០០០ និងសំណុំធាតុអ្នកស្លាប់ត្រូវបានរក្សាទុក។

អ្នករងគ្រោះដែលនៅរស់បានប្រឈមនឹងអតីតកាលនៃភាពឃោរឃៅ និងការចងចាំដោយការនិយាយជាប្រវត្តិសាស្ត្រផ្ទាល់មាត់ ក៏ដូចជាតាមទម្រង់សិល្បៈ កំណាព្យ និងការសម្តែងសិល្បៈល្ខោន។

លោក ប៉ាន់ រិទ្ធី និងសហស្ថាបនិកសមាគម NEVER AGAIN លោក Rafal Pankowski នៅក្នុងព្រឹត្តិការណ៍ភាពយន្តរឿង «រូបភាពដែលបាត់បង់៖ ការគិតគូរឡើងវិញអំពីការសិក្សាអំពើប្រល័យពូជសាសន៍ និងការការពារ» ដែលរៀបចំដោយសមាគមអ្នកសិក្សាពីអំពើប្រល័យពូជសាសន៍អន្តរជាតិ ភ្នំពេញ ឆ្នាំ២០១៩ (ប្រភព៖ សមាគម NEVER AGAIN)។



នៅក្នុងឆ្នាំ២០១៥ បូជនីយដ្ឋានមួយបានសាងសង់ឡើងដើម្បីរំឭកការចងចាំចំពោះអ្នករងគ្រោះដែលត្រូវស្លាប់នៅមន្ទីរសន្តិសុខ ស-២១។
(ប្រភព៖ សមាគម NEVER AGAIN, Wikimedia Commons)






បន្ទប់ឃុំឃាំង និងធ្វើទារុណកម្ម មន្ទីរសន្តិសុខ ស-២១ ទួលស្លែង។
(ប្រភព៖ សមាគម NEVER AGAIN, Wikimedia Commons)










TUOL SLENG GENOCIDE MUSEUM
TOYOTA


THE GALLOWS




រូបភាពខាងលើ គឺ លោក ជុំ ម៉ី និងសហស្ថាបនិកសមាគម NEVER AGAIN។ លោក ជុំ ម៉ី គឺជាអ្នករស់រានមានជីវិតម្នាក់ក្នុងចំណោមអ្នកនៅរស់តែមួយចំនួនតូចប៉ុណ្ណោះ ដែលជាប់ទោសនៅមន្ទីរ ស-២១ ដែលមានអ្នកទោសរាប់ពាន់នាក់។ ជុំ ម៉ី គឺជាជាងមេកានិក នៅមុនពេលជាប់គុក។ គាត់នៅរស់ដោយសារខ្មែរក្រហមត្រូវការប្រើគាត់ឲ្យជួសជុលម៉ាស៊ីនអង្គុលីលេខ ប្រើសម្រាប់កត់ត្រាការសួរចម្លើយ។  ទួលស្លែង ឆ្នាំ២០១៨ (ប្រភព៖ សមាគម NEVER AGAIN)

ការផ្ដួចផ្ដើមដ៏មានតម្លៃ បានបង្កើតឡើងដើម្បីរំឭកដល់វិញ្ញាណក្ខន្ធ ការចងចាំអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមរយៈបទភ្លេងចម្រៀង។ ខ្មែរក្រហមព្យាយាមបំផ្លាញបទភ្លេងនិងរបាំប្រពៃណីខ្មែរ។

ប្រពៃណីទាំងនោះ ត្រូវបានបង្កើត និងប្រារព្ធឡើងវិញតាមស្នាដៃការងាររបស់សិល្បៈខ្មែរអមតៈ ដែលកសាងដោយលោក អាន ចនផន ជាកុមារបានរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍៖ https://www.youtube.com/watch?v=UHd៨-zseEaU








Arn Chorn-Pond, a Khmer Rouge survivor
and cofounder of Cambodian Living Arts
(Credit: VOA/Irwin Loy, Wikimedia commons)





កាក់ ចន្ទី (ប្រភព៖  Julien Poulson, គម្រោងកម្ពុជា Space Project)

ក្រុមរ៉ក់ ជាគម្រោងរបស់កម្ពុជា Space Project បានខិតខំស្តារនិងរំឭកឡើងវិញនូវអនុការចងចាំនៃតន្ត្រី រ៉ក់ អេន រ៉ូល និងទស្សនីយភាពតន្ត្រី ប៉ុប ដែលពេញនិយមខ្លាំងកាលពីនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ និង១៩៧០ ដោយបានរួមបញ្ចូលឥស្សរជនល្បីៗដូចជា **តារាអ្នកនាង រស់ សេរីសុជា ដែលបានស្លាប់ដោយសារខ្មែរក្រហម។ តារាចម្រៀងនាំមុខរបស់ Cambodian Space Projec**t អ្នកនាង កាក់ ចាន្ទី បានរងគ្រោះថ្នាក់បាត់បង់ជីវិតនៅក្នុងឆ្នាំ២០១៨។ មរតករបស់នាងនៅតែមាន។

ចូលទៅស្តាប់ The Cambodian Space Project:  https://www.youtube.com/watch?v=noM៨២VINHRE

## តួនាទីរបស់កម្ពុជានៅក្នុងសង្គ្រាមលោកលើកទីពីរ៖ តើមានទេ? ក្នុងទម្រង់ជាអ្វី?

ចាប់ពីចុងសតវត្សរ៍ទី១៩ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី២០ ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយអាណានិគមបារាំង។ ក្នុងអំឡុងពេលសង្គ្រាមលោកលើកទីពីរ របប Vichy របស់បារាំង (ដែលស្ថិតក្រោមបង្គាប់របស់ណាហ្ស៊ីអាល្លឺម៉ង់) បានបន្តការត្រួតត្រាលើប្រទេសកម្ពុជា និងប្រទេសផ្សេងទៀតនៅឥណ្ឌូចិន other parts of Indochina។ ពេលនោះ អាជ្ញាធរអាណានិគមបារាំងបាននាំចូលចលនានយោបាយលទ្ធិហ្វាស៊ីសមកប្រទេសកម្ពុជា។ ហ្វាស៊ីសនិយមមានអ្នកគាំទ្រជាអ្នកសកម្មជនកម្ពុជាដែលមើលឃើញលទ្ធិនោះថាជាទស្សនៈបែបសម័យទំនើប។ អភិបាលជនជាតិបារាំង ឈ្មោះ Jean Decoux បានដឹកនាំឲ្យបង្កើតចលនាយុវជនខ្មែរ យុវ៉ាន់ (Yuvan) (ផ្អែកលើទ្រឹស្តីគំរូអឺរ៉ុប បំពេញដោយនិមិត្តសញ្ញាដូចជា «Roman salute»)។ ការដកថ្មីហ្វពីអាណានិគម ត្រូវបានអមដោយការផ្សព្វផ្សាយនូវការឃោសនាប្រឆាំងជនជាតិថ្វីហ្វ ដែលបញ្ជាក់ពីវិបស្សនាស្តាំនិយមជ្រុលរបស់អាណាព្យាបាលបារាំងនៅក្នុងប្រទេសក្រោមអាណានិគម។

បន្ទាប់ពីការគ្រប់គ្រងរបស់អាណានិគមបារាំងត្រូវបានជប៉ុនមកបន្ត ចលនាជាតិជ្រុលនិយមក៏បានកើតឡើងដោយក្រសោបយកឱកាសរីកដុះដាល។ ចលនាគាំទ្រជប៉ុនជ្រុលនិយមនេះ ក៏បានពង្រីកឥទ្ធិពលរបស់ខ្លួន និងធ្វើរដ្ឋប្រហារនៅក្នុងខែសីហា ឆ្នាំ១៩៤៥។ ពួកគេបានបន្តកាន់អំណាចរហូតដល់ខែតុលា ឆ្នាំ១៩៤៥ នៅពេលបារាំងមកគ្រប់គ្រងឡើងវិញ។ នេះគឺជាករណីពិសេសមួយនៃចលនាគាំទ្រហ្វាស៊ីស តាមកាន់អំណាចក្នុងរយៈកាលចុងក្រោយនៃសង្គ្រាមលោកលើកទីពីរ។
នៅក្នុងប្រទេសកម្ពុជា មិនសូវមានការចងចាំទូលំទូលាយអំពីសង្គ្រាមលោកលើកទីពីរទេ ហើយក៏មិនមានបូជនីយដ្ឋាន ឬទីសក្ការរំឭកពីសម័យនោះនៅក្នុងប្រទេសដែរ។ ឧទាហរណ៍មួយដែលត្រូវបានស្គាល់ពីការរំឭកនៃជម្លោះនេះ គឺការបោះពុម្ពកំណត់ហេតុរបស់ អាន់ ហ្វ្រែង ជាភាសាខ្មែរ។

បន្ទាប់មកទៀត ការចងចាំពីសង្គ្រាមលោកលើកទីពីរ នៅក្នុងប្រទេសកម្ពុជា ត្រូវបានលុបបំបាត់ដោយព្រឹត្តិការសោកនាដកម្មផ្សេងៗ៖ សង្គ្រាមស៊ីវិលកម្ពុជា និងអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម។

ប៉ុន្តែ យោងតាមកំណត់ប្រវត្តិរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ដែលបានចេញផ្សាយនៅក្នុងឆ្នាំ១៩៨០ បានឲ្យដឹងថា មេដឹកនាំខ្មែរក្រហម ប៉ុល ពត បានបង្ហាញពីភាពឈ្លក់វង្វេងនឹង អាដាហ្វ ហ៊ីត្លែរ នៅក្នុងសន្ទរកថារបស់ខ្លួន និងក្នុងការនិយាយស្តីជាសម្ងាត់។

## សំណួរសម្រាប់ត្រិះរិះពិចារណា៖

**មើលរូបថតបូជនីយដ្ឋានពីរ៖ រូបសំណាកជនរងគ្រោះនៅគុកទួលស្លែង ជាស្នាដៃរបស់សិល្បករខ្មែរកាត់បារាំង Sera Ing និងរូបសំណាករង្វង់មូលស្តីពីការផ្តួលរលំខ្មែរក្រហមដោយវៀតណាម។ តើបូជនីយដ្ឋានទាំងពីរនេះ មានតួនាទីអ្វីក្នុងការកសាងការចងចាំជាសហភាពរួមអំពីខ្មែរក្រហមនិងអំពើឃោរឃៅរបស់វា?**



សមាជិករបស់អង្គការយុវជន យុវ៉ាន់ ដើរក្បួនធម្មយាត្រាគាំទ្ររដ្ឋាភិបាល Vichy នៅក្នុងប្រទេសបារាំង។ (John Tully ប្រវត្តិសាស្ត្រខ្លីស្តីពីកម្ពុជា៖ ពីសម័យអាណាចក្រ ទៅដល់ការរស់រាន។ ឆ្នាំ២០០៦) Allen & Unwin)






រូបសំណាករបស់ជនរងគ្រោះនៅគុលស្លែង ស្នាដៃដោយសិល្បករកម្ពុជាបារាំង Sera Ing និងរូបសំណាករង្វង់មូលអបអរដល់ការដួលរលំនៃរបបខ្មែរក្រហម សាងសង់ដោយវៀតណាម (ប្រភព៖ Wikimedia Commons)

## ទស្សនៈសង្គមចម្រុះភាពខុសគ្នា ក្រុមជនជាតិភាគតិចសំខាន់ៗនៅក្នុងប្រទេស ករណីនៃការធ្វើទុក្ខបុកម្នេញក្រោយឆ្នាំ១៩៤៥

ទោះបីជាវត្តមានរបស់ក្រុមជនជាតិភាគតិចមាននៅក្នុងប្រទេសក៏ដោយ ប្រជាជនកម្ពុជាភាគច្រើនជាអ្នកកាន់សាសនាព្រះពុទ្ធ។ ក្រុមជនជាតិភាគតិចដែលច្រើនជាងគេនៅក្នុងប្រទេសកម្ពុជា គឺសហគមន៍ចាមមូស្លីម ចិន និងវៀតណាម ព្រមទាំងក្រុមជនជាតិដើមតូចៗមួយចំនួនទៀត ដូចជាខ្មែរក្រោម និងកួយ។ នៅក្រោមរបបខ្មែរក្រហម ជនជាតិចាម និងវៀតណាម ត្រូវបានកំណត់ជាគោលដៅសម្លាប់។ នៅក្នុងឆ្នាំ២០១៨ ខៀវ សំផន ជាមេដឹកនាំខ្មែរក្រហមចុងក្រោយដែលនៅរស់ ត្រូវបានតុលាការអន្តរជាតិកាត់ក្តីខ្មែរក្រហម កាត់ទោសពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅលើចាមមូស្លីម និងជនជាតិភាគតិចវៀតណាមនៅកម្ពុជា។

ស្វែងរកព័ត៌មានបន្ថែម៖ Minorities and indigenous people in Cambodia



ប្រទេសកម្ពុជាមានមស្ជិតចំនួន៨៨៤ និងសាលាសាសនាឥស្លាមចំនួន៣១៤កន្លែង (រូបថតដោយ៖ សើ សាយ្យាណា)



Gathering of Muslim men in Cambodia (Credit: Sayana Ser)

### សំណួរសម្រាប់ត្រិះរិះពិចារណា៖

**១ តើសង្គ្រាមអាចប៉ះពាល់ដល់ក្រុមជនជាតិភាគតិចដោយរបៀបណា? តើពួកគេជាក្រុមដែលងាយរងគ្រោះរងឬ?**
**២ តើមានវិធានការបង្ការអ្វីខ្លះដែលអាចការពារក្រុមភាគតិចនៅពេលមានជម្លោះ?**

# ប្រភេទនៃការបដិសេធន៍ និងបំផ្លែងទ្រង់ទ្រាយហូឡូខស៍ និងអំពើប្រល័យពូជសាសន៍

## អ្នកពហុបដិសេធ

វិធីសាស្ត្រវាក់កំផែលមួយចំនួនរបស់អ្នកបដិសេធហូឡូខសត៍  មានភាពប្រហាក់ប្រហែលគ្នានឹងវិធីសាស្ត្រដែលប្រើដោយអ្នកបដិសេធអំពីអំពើប្រល័យពូជសាសន៍កម្ពុជា។  ក្នុងករណីខ្លះ  ការបដិសេធន៍និងបំផ្លែងទ្រង់ទ្រាយទាំងពីរនោះ ត្រូវបានលើកឡើងដោយមជនតែមួយ ដែលអាចហៅថាជា**អ្នកពហុបដិសេធ**។

១

**ខៀវ សំផន** គឺជាប្រមុខរដ្ឋដែលជ្រើសតែងតាំងក្នុងអំឡុងរបបខ្មែរក្រហម ដែលក្រោយមក ត្រូវបានកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ការសរសេររបស់ ខៀវ សំផន គឺជាឧទាហរណ៍គំរូមួយស្តីពីការបដិសេធន៍អំពើប្រល័យពូជសាសន៍ ឬការបំផ្លែងទ្រង់ទ្រាយ៖ សំភារៈឯកសារដែលអ្នកនិពន្ធរូបនេះប្រើប្រាស់ដើម្បីវែកញែក មានលក្ខណៈដូចគ្នាខ្លាំងទៅនឹងសម្ភាររបស់អ្នកបដិសេធ ឬបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ប្រើនៅអឺរ៉ុបដែរ។ ខៀវ សំផន ប្រានចោលកំហុស ដូច Michael Shafir ក្នុងករណីបដិសេធនិងបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ នេះជាយុទ្ធសាស្ត្រមួយដែលអ្នកសិក្សាបានកំណត់ឃើញ។ ខៀវ សំផន ប៉ុនប៉ងរុញទម្លាក់កំហុសទៅឲ្យអ្នកផ្សេង ដូចជា ប៉ុល ពត និង វៀតណាម ដោយអះអាងថា ឧក្រិដ្ឋកម្មដ៏អាក្រក់ និងភាពឃោរឃៅទាំងនោះ មិនមែនខ្មែរក្រហមជាអ្នកប្រព្រឹត្ត ប៉ុន្តែ គឺជាកងទ័ពវៀតណាម។ ការរុញដាក់កំហុសនេះ ជាលក្ខណៈច្បាស់លាស់របស់អ្នកបដិសេធនិងបំផ្លែងទ្រង់ទ្រាយហូឡូខសត៍នៅអឺរ៉ុប។



សវនាការដំបូងសំណុំរឿង០០២ ខៀវ សំផន
(ប្រភព៖ Wikimedia Commons)



ប្រមុខរដ្ឋខ្មែរក្រហម ខៀវ សំផន ឆ្នាំ១៩៧៨
(ប្រភព៖ Wikimedia Commons)

២

**Jacques Verges** ដែលមានដើមកំណើតជនជាតិថៃ បានការពារជនជាប់ចោទជាច្រើន ដូចជាឧក្រិដ្ឋជន និងអ្នកប្រើអំណាចផ្តាច់ការ។ ដូចគ្នានឹងជាតំណាងឲ្យមេដឹកនាំខ្មែរក្រហម លោកក៏បានការពារ Klaus Barbie ដែលជាឧក្រិដ្ឋជនឃោរឃៅរបស់ណាហ្ស៊ីផងដែរ ដែលត្រូវបានចាប់ខ្លួននិងកាត់ទោសនៅក្នុងទសវត្សឆ្នាំ១៩៨០ ពីបទមានតួនាទីក្នុងការសម្លាប់បំបាត់ជនជាតិជ្វីហ្វបារាំង។ នៅក្នុងការការពារមេដឹកនាំខ្មែរក្រហម លោក Verges បានទាញយកវិធីសាស្រ្តប្រហាក់ប្រហែលនឹងការបដិសេធន៍អំពើប្រល័យពូជសាសន៍ ឬការបង្រួមឲ្យស្រាល និងធ្វើឲ្យរាក់កំផែល។

៣

**Jan Myrdal** គឺជាអ្នកនិពន្ធ សកម្មជន និងឥស្សរជនស៊ុយអែតមួយរូប បានបង្ហាញយ៉ាងច្បាស់ពីវិសមានចិត្តស្អប់ខ្ពើមជនជាតិជ្វីហ្វ និងជាពិសេស ប្រឆាំងនឹងអ៊ីស្រាអែល។ លោកចាប់អារម្មណ៍នឹងរបបខ្មែរក្រហម ហើយបានចូលរួមពាក់ព័ន្ធជាច្រើនឆ្នាំ ក្នុងការបដិសេធការពិតនៃឧក្រិដ្ឋកម្មនៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានជំរុញឲ្យមានការប្រឆាំងចលនាការពារនិងអភិវឌ្ឍជ្វីហ្វ ក្នុងលក្ខណៈបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ ដោយអះអាងថាប្រទេសអ៊ីស្រាអែលកំពុងបំផ្លើសពីរឿងហូឡូខសត៍ដើម្បីផលប្រយោជន៍ខ្លួនផ្ទាល់។



***Jan Myrdal*** (Credit: Wikimedia Commons)



ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១៖ លោក Jacques Verges មេធាវីអន្តរជាតិការពារ ខៀវ សំផន អំឡុងពេល ថ្ងៃដំបូងនៃការបើកអង្គសេចក្តីក្នុងសំណុំរឿង០០២
(Credit: Wikimedia Commons)

## ៤

**Israel Shamir** មានដើមកំណើតជាជ្វីហ្វរុស្សី និងបានរស់នៅក្នុងប្រទេសមួយចំនួន រួមមានប្រទេសអ៊ីស្រាអែល និងប្រទេសស៊ុយអែត គឺជាគំរូតំណាងមួយនៃចលនាប្រឆាំងជនជាតិជ្វីហ្វក្នុងសម័យបច្ចុប្បន្ននេះ។ លោកចោទប្រកាន់ជ្វីហ្វនិងអ៊ីស្រាអែលថាបំផ្លើសពីរឿងហូឡូខសត៍ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន។ លោកក៏បានសរសេរអត្ថបទអះអាងថាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តដោយខ្មែរក្រហម មិនបានកើតឡើងនោះទេ។ លោកនេះគឺជាឧទាហរណ៍ដ៏សំខាន់មួយនៃអ្នកពហុបដិសេធ ដែលមិនទទួលស្គាល់ ឬសម្រាលកម្រិតអំពើប្រល័យពូជសាសន៍ និងការរំលោភបំពានសិទ្ធិមនុស្ស ទាំងនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទីពីរ និងនៅក្នុងប្រទេសកម្ពុជា ក្នុងទសវត្សឆ្នាំ១៩៧០។

## ៥

**Naom Chomsky** គឺជាបញ្ញវន្តដ៏សំខាន់មួយរូបនៃសម័យនេះ។ លោកមិនមែនជាអ្នកបដិសេធពីអំពើប្រល័យពូជសាសន៍ ប៉ុន្តែសេចក្តីថ្លែងរបស់លោកមួយចំនួន ដែលលោកបានលើកឡើងនៅចុងទសវត្សឆ្នាំ១៩៧០ អាចបកស្រាយជាការសម្រាលកម្រិតឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម។ ចាប់តាំងពីនោះមក លោកបានដកពាក្យសំដីមួយចំនួនដែលបានថ្លែង។ ទោះយ៉ាងណាក៏ដោយ តួនាទីរបស់លោកនៅពេលនោះ ពាក់ព័ន្ធនឹងបញ្ហាអំពើប្រល័យពូជសាសន៍នៅកម្ពុជា នៅតែជាបញ្ហា ដូចគ្នានឹងសេចក្តីថ្លែងរបស់លោកមួយចំនួនទៀត ពាក់ព័ន្ធនឹងការបដិសេធន៍ពីហូឡូខសត៍។ Chomsky បានសរសេរអារម្ភកថានៅក្នុងសៀវភៅមួយដែលនិពន្ធដោយ Robert Faurisson ជាជនជាតិបារាំងបដិសេធហូឡូខសត៍ ដែលត្រូវបានបញ្ឈប់ពីមុខងារបង្រៀននៅសកលវិទ្យាល័យ និងត្រូវបាននាំទៅតុលាការជំនុំជម្រះពីការបដិសេធថាណាហ្ស៊ីមិនមានឃ្លាំងឧស្ម័នដុតមនុស្ស។ Chomsky បានអះអាងថា លោកសរសេរសន្ទរកថានោះ ក្នុងនាមសេរីភាពនៃការបញ្ចេញមតិ ប៉ុន្តែ លោកត្រូវបានរិះគន់យ៉ាងធ្ងន់ទៅលើការយល់ស្របឲ្យមានទម្រង់បដិសេធនិងបំផ្លែងទ្រង់ទ្រាយហូឡូខសត៍ ក៏ដូចជាអំពើប្រល័យពូជសាសន៍នៅកម្ពុជា។



***Naom Chomsky***
(Credit: Augusto Starita / Ministerio de Cultura de la Nacion/Wikimedia Commons)




***Israel Shamir*** (Credit: Wikimedia Commons)

### សំណួរសម្រាប់ត្រិះរិះពិចារណា៖

**តើបែបផែននៃការបំផ្លែងទ្រង់ទ្រាយ និងបដិសេធអំពីអំពើប្រល័យពូជសាសន៍អាចនាំឲ្យមានទម្រង់ផ្សេងទៀតឬទេ?**

**តើភាពប្រហាក់ប្រហែលគ្នារវាងទម្រង់ផ្សេងៗនៃការបំផ្លែងទ្រង់ទ្រាយ និងបដិសេធនូវអំពើប្រល័យពូជសាសន៍នៅលើពិភពលោក មានអ្វីខ្លះ?**

## សម្ភារមូលដ្ឋានដែលកម្ពុជាអាចយកមកទប់ទល់នឹងការបំផ្លែងទ្រង់ទ្រាយ និងការបដិសេធន៍៖ បញ្ហាទទួលខុសត្រូវ និងការតស៊ូប្រឆាំងនឹងខ្មែរក្រហម

តាមរយៈដំណើរស្មុគស្មាញទាក់នឹងការប្រឈមនឹងអតីតកាល ប្រជាជនកម្ពុជាអាចនិយាយពិភាក្សាពីបញ្ហាលំបាកលំបិនដូចជា ការទទួលខុសត្រូវរបស់ពួកគេផ្ទាល់នៅក្នុងរបបខ្មែរក្រហម ក៏ដូចជាការតស៊ូរបស់ប្រជាជននៅអំឡុងពេលអំពើប្រល័យពូជសាសន៍។
ភាពធន់របស់អ្នករស់រានពីហូឡ្វខសត៍ អាចធ្វើជាសំអាង និងកម្លាំងចិត្តដល់ប្រជាជនកម្ពុជាក្នុងការពុះពារជំនះលើទុក្ខលំបាកអតីតកាលរបស់ខ្លួន។

ការតស៊ូកើតមានឡើងនៅក្នុងរបបខ្មែរក្រហម ហើយអ្នកចំនួនមិនព្រមនៅស្ងៀមឡើយ នៅពេលមានអំពើឃោរឃៅទាំងនោះ។ សូមអានរឿងរ៉ាវរបស់ បុប្ផាណា Bophana ជាស្ត្រីវ័យ២៥ឆ្នាំមួយរូប ដែលបានសរសេរសំបុត្រ គេហាមឃាត់ នៅក្នុងគុក និងត្រូវបានខ្មែរក្រហមសម្លាប់។




បុប្ផាណា (ប្រភព៖ មជ្ឈមណ្ឌលបុប្ផាណា)

# រឿងរ៉ាវស្ដីពីការតស៊ូ និងភាពធន់របស់ស្ត្រីជនជាតិភាគតិច នៅក្រោមរបបខ្មែរក្រហម

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ៧០%ជាស្ត្រី ភាគច្រើនជាស្ត្រីមេម៉ាយ។ ចាប់តាំងពីរបបខ្មែរក្រហមដួលរលំក្នុងឆ្នាំ១៩៧៩ ស្ត្រីគឺជារួបរួមសង្គមដ៏សំខាន់ និងជាអ្នកកសាងប្រទេសជាតិ ដោយបង្កើតទម្រង់សេដ្ឋកិច្ចឡើងវិញ នៅអំឡុងពេលចលាចលក្នុងទសវត្សឆ្នាំ១៩៨០ និង១៩៩០ នៅពេលសង្គ្រាមស៊ីវិលជាមួយខ្មែរក្រហម និងទណ្ឌកម្មសេដ្ឋកិច្ចត្រូវបានរឹតបន្តឹងឱកាសអភិវឌ្ឍ។
លើសពីនេះទៅទៀត តាមរយៈការប្រឹងប្រែងឥតរួញរារបស់ស្ត្រីទាំងអស់នេះហើយ ដែលនាំឲ្យវប្បធម៌ ប្រពៃណីកម្ពុជា និងការអប់រំកកើតមានឡើងវិញនៅក្នុងរចនាសម្ព័ន្ធសង្គមជីវិតប្រចាំថ្ងៃ។ ស្ថិតក្រោមកាលៈទេសៈលំបាកទាំងនេះ ស្ត្រីកម្ពុជាបង្ហាញនូវភាពធន់ និងកម្លាំងដ៏អស្ចារ្យ។

មានរឿងរ៉ាវរបស់ស្ត្រីកម្ពុជាដែលនៅរស់រានមានជីវិត ត្រូវប្រឈមនឹងអតីតកាល ការឈឺចាប់ ទុក្ខវេទនា និងការបាត់បង់។ នៅទីនេះគឺជារឿងរ៉ាវរបស់ស្ត្រីមេម៉ាយពីរនាក់ដែលបានទទួលរងទុក្ខយ៉ាងខ្លាំងនៅក្នុងរបបខ្មែរក្រហម និងបានតស៊ូរស់ដោយដើម្បីកូនៗ និងសាច់ញាតិរបស់ពួកគេ។

**សឹម ម៉ារីយ៉ាស់ (សែម ម៉ារី) អាយុ ៧៣ឆ្នាំ**

សឹម ម៉ារីយ៉ាស់ គឺជាស្ត្រីមូស្លីមកម្ពុជាដែលមានដើមកំណើតជ្វាម៉ាឡេ។ គាត់គឺជាកូនច្បងក្នុងចំណោមបងប្អូន១២នាក់ ក្នុងគ្រួសារឈ្មួញអ្នកលក់ដូរ។ គាត់បានរៀបការជាមួយលោក ឡុង សើ ជាខ្មែរកាត់ចិន និងមានកូនប្រុសបួននាក់ និងកូនស្រីមួយ។
នៅក្នុងរបបខ្មែរក្រហម ម៉ារីយ៉ាស់ បានប្តូរឈ្មោះទៅជា សែម ម៉ារី ដោយខ្លាចត្រូវបង្ខំឲ្យស៊ីសាច់ជ្រូក និងត្រូវទទួលរងការបង្ខិតបង្ខំផ្សេងទៀត ប្រសិនបើពួកខ្មែរក្រហមបានដឹងថាគាត់នៅតែមានជំនឿលើសាសនា។ គាត់ក៏ដូចជាស្ត្រីផ្សេងទៀត នៅក្នុងរបបនោះដែរ គឺត្រូវបង្ខំឲ្យកាត់សក់ខ្មៅវែងរបស់គាត់។ ប្អូនស្រីៗរបស់គាត់ដែលមានវ័យជំទង់ មានអាយុ១៣ទៅ១៨ឆ្នាំ ត្រូវលាក់អត្តសញ្ញាណដោយកុហកថាពួកគេបានរៀបការ ហើយប្តីរបស់ពួកគេត្រូវបញ្ជូនទៅធ្វើការនៅកងផ្សេង។
ខ្មែរក្រហមមិនអនុញ្ញាតឲ្យមានជំនឿផ្ទាល់ខ្លួន និងម្ចាស់កម្មសិទ្ធិឯកជន ឬទ្រព្យសម្បត្តិអ្វីឡើយ គឺគ្រប់យ៉ាងជារបស់ អង្គការ រួមទាំងកូនក្មេង។ ពួកគេត្រូវធ្វើការនៅសហករណ៍ និងវាលស្រែ ជញ្ជូនស្បៀងទៅឲ្យទាហាននៅសមរភូមិមុខ។ សិទ្ធិសេរីភាពរបស់ពួកគេ ត្រូវដកហូត និងបំបែកចេញពីឪពុកម្តាយ។

នៅក្នុងរបបខ្មែរក្រហម ម៉ារីយ៉ាស់ បានប្តូរឈ្មោះទៅជា សែម ម៉ារី ដោយខ្លាចត្រូវបង្ខំឲ្យស៊ីសាច់ជ្រូក និងត្រូវទទួលរងការបង្ខិតបង្ខំផ្សេងទៀត ប្រសិនបើពួកខ្មែរក្រហមបានដឹងថាគាត់នៅតែមានជំនឿលើសាសនា។ គាត់ក៏ដូចជាស្ត្រីផ្សេងទៀត នៅក្នុងរបបនោះដែរ គឺត្រូវបង្ខំឲ្យកាត់សក់ខ្មៅវែងរបស់គាត់។ ប្អូនស្រីៗរបស់គាត់ដែលមានវ័យជំទង់ មានអាយុ១៣ទៅ១៨ឆ្នាំ ត្រូវលាក់អត្តសញ្ញាណដោយកុហកថាពួកគេបានរៀបការ ហើយប្តីរបស់ពួកគេត្រូវបញ្ជូនទៅធ្វើការនៅកងផ្សេង។
ខ្មែរក្រហមមិនអនុញ្ញាតឲ្យមានជំនឿផ្ទាល់ខ្លួន និងម្ចាស់កម្មសិទ្ធិឯកជន ឬទ្រព្យសម្បត្តិអ្វីឡើយ គឺគ្រប់យ៉ាងជារបស់ អង្គការ រួមទាំងកូនក្មេង។ ពួកគេត្រូវធ្វើការនៅសហករណ៍ និងវាលស្រែ ជញ្ជូនស្បៀងទៅឲ្យទាហាននៅសមរភូមិមុខ។ សិទ្ធិសេរីភាពរបស់ពួកគេ ត្រូវដកហូត និងបំបែកចេញពីឪពុកម្តាយ។

ឪពុករបស់ម៉ារី បានឈឺស្លាប់ដោយសារគ្មានការព្យាបាលក្នុងសម័យខ្មែរក្រហម។ ម៉ារីក៏បានបាត់បង់កូនប្រុសពីរនាក់ និងកូនស្រីម្នាក់ដោយជំងឺ និងខ្វះជីវជាតិអាហារមិនគ្រប់គ្រាន់។ ខ្មែរក្រហមបានយក ឡុង សើ ប្តីរបស់គាត់ទៅសម្លាប់នៅក្បែររណ្តៅមួយក្នុងខេត្តកណ្តាល ដោយសារគាត់ចុះខ្សោយអស់កម្លាំងពីការធ្វើការហួសហេតុនៅវាលស្រែ និងសង់ទំនប់ទឹក ប្រព័ន្ធធារាសាស្ត្រ។
ខ្មែរក្រហមចាត់ទុកអ្នកណាដែលទន់ខ្សោយ ឬឈឺពេលធ្វើការនៅស្រែ ឬអ្នកណាដែលមិនដឹងពីរបៀបដាំស្រូវ គឺជាអ្នកទីក្រុង គឺអ្នកដែលមានស្បែកស ឬពាក់វ៉ែនតា ត្រូវចាត់ទុកថាជាដង្កូវជន្លេនសង្គម ជាពួកមូលធននិយម ឬជាខ្មាំង។



សែម ម៉ារី និងប្អូនស្រី សែម សុធា រូបថតនៅមុនរបបខ្មែរក្រហម ក្នុងឆ្នាំ១៩៧៤ នៅហាង «កម្ពុជាថតរូប» របស់លោក អ៊ីវ៉ុង ហែម នៅមុខផ្សារថ្មី
(រូបថតផ្តល់ដោយ៖ សើ សាយ្យាណា)

ខ្មែរក្រហមក៏ជិតនឹងយកជីវិតរបស់ម៉ារីទៅដែរ នៅពេលគាត់អង្វរសុំពួកគេពីដំណឹងប្តីរបស់គាត់។ «គេអូសខ្ញុំយកទៅសម្លាប់ដែរ។ ខ្ញុំគិតថាខ្ញុំស្លាប់ហើយនៅពេលនោះ ដោយសារខ្ញុំព្យាយាមសួរពួកវាពីប្តីខ្ញុំ ប៉ុន្តែកូនប្រុសតូចៗរបស់ខ្ញុំពីរនាក់ អាយុ៦ឆ្នាំ និង៨ឆ្នាំ យំឱបជើងអង្វរពួកខ្មែរក្រហមហ្នឹងឲ្យលែងខ្ញុំ៖ «សូមលែងម្តាយខ្ញុំទៅ។ ប្រសិនបើយកគាត់ទៅ គ្មានអ្នកណាមើលថែខ្ញុំទេ សូមអាណិតពួកយើងផង...»។ ខ្មែរក្រហមក៏បានដោះលែង ម៉ារី ដោយប្រមាន និងយកកាំភ្លើងវៃក្បាលរបស់គាត់ឡើងចេញឈាម។ ឈ្លបខ្មែរក្រហមក៏បានទាញសក់អូសម៉ារីទៅជិតរណ្តៅដែរ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ម៉ារី បានជួបជុំជាមួយម្តាយនិងបងប្អូន និងត្រូវមើលថែចិញ្ចឹមសមាជិកគ្រួសារចំនួនប្រាំបួននាក់ ដែលមានម្តាយមេម៉ាយ កូនប្រុសពីរនាក់ ប្អូនប្រុសម្នាក់ ប្អូនស្រីៗចំនួនបួននាក់ និងក្មួយស្រីតូចម្នាក់ដែលកំព្រាឪពុកម្តាយដោយត្រូវខ្មែរក្រហមសម្លាប់។ ម៉ារី ខិតខំប្រកបរបរដើរលក់ដូរថ្នាំឫសឈើ និងក្រណាត់ខោអាវ ដែលគាត់បានរៀនចេះពីឪពុករបស់គាត់។ គាត់ធ្វើដំណើរទៅលក់ដូរតាមខេត្តនានា ដោយដើរពីផ្ទះមួយទៅផ្ទះមួយ និងសុំផ្ទះអ្នកភូមិគេងស្នាក់ពីរបីយប់។ ម៉ារីបានជួបនឹងការលំបាក និងទទួលរងទុក្ខខ្លាំង ប៉ុន្តែបានព្យាយាមជំនះតស៊ូនឹងឧបសគ្គទាំងអស់ ដើម្បីថែរក្សាគ្រួសារមនុស្សជាទីស្រឡាញ់ ដែលពឹងផ្អែកលើគាត់ ដោយសារពួកគេនៅតូចៗ និងកំព្រា។ កូនប្រុសនិងប្អូនប្រុសរបស់គាត់បានរៀននៅសាលា និងបញ្ចប់ថ្នាក់ឧត្តមសិក្សា នៅក្រៅប្រទេស។ ការខិតខំរបស់គាត់បានផ្តល់ផលមកវិញ ហើយប្អូនស្រីៗ និងក្មួយស្រីក៏បានរៀបការមានគ្រួសាររៀងខ្លួន។

ទោះបីជាសព្វថ្ងៃ ម៉ារី កំពុងរស់នៅមានសេរីភាពជាមួយគ្រួសារកូនប្រុសច្បង កូនប្រសារស្រី និងចៅៗក៏ដោយ ក៏ស្ថានភាពរាងកាយសុខភាពផ្លូវចិត្តរបស់គាត់មានលក្ខណៈទន់ខ្សោយ ដោយស្រមោលនៃការរងទុក្ខឈឺចាប់ពីអតីតកាល នៅតែដាមជាប់ក្នុងការចងចាំរបស់គាត់។

«ប្តីខ្ញុំជាមនុស្សល្អស្លូតបូត។ គាត់មានស្បែកសស្អាត ដោយសារគាត់ជាកូនចៅចិន។ ពួកយើងស្រឡាញ់គ្នាណាស់។ ទាល់រាល់ថ្ងៃនេះ ខ្ញុំយល់សប្តិឃើញមុខគាត់។ ខ្ញុំចង់ជួបគាត់ណាស់ ស្រមៃឃើញមុខគាត់ ជីវិតយើងមិនដឹងប្រែទៅជាយ៉ាងម៉េច ប្រសិនបើគាត់នៅរស់វិញ»។

ក្រោយពេលរបបខ្មែរក្រហមបានដួលរលំ ទីរាម បានជួបជុំជាមួយនឹងបងប្អូន កូនៗ និងក្មួយៗបានខ្លះ ហើយបានបន្តស្វែងរកសមាជិកគ្រួសាររបស់គាត់ទៀត។ គាត់បានចិញ្ចឹមមើលថែក្មួយៗកំព្រាចំនួនប្រាំពីរនាក់ ដែលឪពុកម្តាយត្រូវខ្មែរក្រហមយកទៅសម្លាប់។



ម៉ារី (ឆ្វេង ទី១) សុជា (ស្តាំ ទី១) ថតជាមួយម្តាយ និងប្អូនៗប្រុសស្រីនៅក្នុងពិធីការក្មួយប្រុស។ (Credit: Family archive of Sayana Ser)



ម៉ារី និងចៅៗ ថតនៅមុខផ្ទះ។ គាត់មានជំងឺសន្លាក់ និងឈឺចង្កេះ។
(Credit: Family archive of Sayana Ser)

ទីរាមបានបាត់បង់សមាជិកគ្រួសារអស់ជាច្រើននាក់នៅក្នុងរបបខ្មែរក្រហម។ ប្ដីរបស់គាត់គឺជាមន្ត្រីរាជការ ត្រូវខ្មែរក្រហមចោទថាជាជនក្បត់ និងត្រូវបញ្ជូនទៅអប់រំ គឺមានន័យថា យកទៅសម្លាប់។ បងថ្លៃប្រុសរបស់ ទីរាម គឺជាមន្ត្រីគយនៅក្នុងរបប លន់ នល់ ហើយត្រូវខ្មែរក្រហមសម្លាប់ទាំងពីរនាក់ប្ដីប្រពន្ធជាបងស្រីរបស់ទីរាម។ បន្សល់នៅកូនស្រីកំព្រារពីរនាក់។ បងប្អូនរបស់ទីរាម បីនាក់ទៀត ដែលជាមន្ត្រីនៅក្នុងរបបចាស់ ក៏ត្រូវបានខ្មែរក្រហមតាមដានចាប់ រួមទាំងប្អូនប្រុសរបស់ ទីរាម ដែលជានិស្សិតក៏ត្រូវចាប់យកទៅសម្លាប់ដែរ។

ពាក្យស្លោករបស់ខ្មែរក្រហមមួយនិយាយថា «គ្មានសញ្ញាបត្រទេ មានតែសញ្ញាឃើញ។ ប្រសិនបើចង់បានសញ្ញាបត្រ ត្រូវតែទៅយកនៅព្រែកជីកទំនប់»។ ពាក្យស្លោកមួយទៀត និយាយថា «ការសិក្សាមិនសំខាន់ទេ។ អ្វីដែលសំខាន់គឺការងារនិងបដិវត្តន៍»។ ដោយហេតុនេះ នៅក្រោមរបបគ្រប់គ្រង ផ្ដាច់ការឃោរឃៅរបស់ខ្មែរក្រហម សាលារៀនត្រូវបានបិទទាំងស្រុង។ របបនេះបានប្រែក្លាយសាលារៀនសាធារណៈ និងវត្តអារាម ទៅជាកន្លែងឃុំឃាំង ក្រោលសត្វ និងឃ្លាំង។

ទីរាម ត្រូវចិញ្ចឹមមើលថែក្មេងប្រុសពីរនាក់ និងក្មេងស្រីប្រាំនាក់។ ក្មួយស្រីម្នាក់មានជំងឺគនិងថ្លង់។ គាត់បានឲ្យពួកគេទៅរៀនចេះអាននិងសរសេរគ្រប់គ្នា។ ចំណែកគាត់តែងតែធ្វើដំណើរទៅមកពីផ្ទះនៅជាយក្រុងភ្នំពេញ និងកន្លែងការងារនៅឆ្នុកទ្រូ នៅខេត្តកំពង់ឆ្នាំង។ គាត់ជាអ្នកប្រមូលទិញលក់ត្រីទឹកសាប និងលៀសខ្មៅនៅបឹងទន្លេសាប។
ទីរាម បានខិតខំប្រឹងប្រែងរកស៊ីយ៉ាងសស្រាក់សស្រាំ ដើម្បីចិញ្ចឹមជីវិត និងបំពេញជីវផាពរស់នៅឲ្យក្មេងៗដែលនៅជាមួយគាត់។ ដោយសារការងារមមាញឹកក្នុងមុខរបរនេះ នាំឲ្យគាត់ចូលចិត្តទុកសក់ខ្លីដូចប្រុស និងច្រើនតែស្លៀកតែខោ។ តាមសម្ដីបងប្អូនរបស់គាត់បានឲ្យដឹងថា ទីរាម ធ្លាប់ជាស្ត្រីដ៏ស្អាតបាតម្នាក់ មានសម្បុរស្បែកសជាងគេក្នុងចំណោមបងប្អូនទាំងអស់ និងមានសក់ខ្មៅរលោងស្អាត ហើយធ្លាប់មានរូបរាងជាលោកស្រីថ្លៃថ្នូ។

បច្ចុប្បន្ន ទោះបីជាក្មួយៗកូនកំព្រារទាំងអស់បានធំពេញវ័យ រៀបការមានគ្រួសារ មានកូនហើយក៏ដោយ (លើកលែងក្មួយស្រីដែលគថ្លង់កំពុងរស់នៅជាមួយបងស្រីច្បងរស់នាង) ទីរាម នៅតែបន្តធ្វើដំណើរប្រកបរបរកស៊ីនេះជារឿយៗ។ សុខភាពរបស់គាត់ធ្លាក់ចុះខ្សោយ និងទ្រុឌទ្រោមខ្លាំងបន្ទាប់ពីកើតស្ត្រូក ដាច់សរសៃឈាម ដែលបណ្ដាលឲ្យគាត់វៀចមុខនិងមាត់មួយចំហៀង។ គាត់បានខំប្រឹងធ្វើចលនាដោយប្រើកម្លាំងខ្លួនឯង និងឧស្សាហ៍ព្យាយាមឥតសម្រាក។

នៅក្នុងរបបក្រហម ទីរាម អាចទុកបានរបស់ពីរយ៉ាងគឺ៖ ភួយដែលគាត់ប្រើជាខ្នើយ ឬជាកម្រាលក្រាលលើដីដើម្បីដេកពេលយប់ និងស្លាបព្រាមួយដែលគាត់បានចងពាក់នឹងកដើម្បីការពារកុំឲ្យត្រូវគេលួច ឬបាត់។



នាក់ ទីរាម (ឆ្វេង) និងមិត្តស្និទ្ធស្នាលដែលមានឈ្មោះហៅក្រៅថា ឡុង យ៉ាស់
(Credit: Family archive of Sayana Ser)



នាក់ ទីរាម ទៅទីក្រុងម៉ាកាស និងចៅប្រុស រ៉ូហ្សាក់ ជូនដំណើរនៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។
(Credit: Family archive of Sayana Ser)

## ៣. ការផ្តួចផ្តើមរបស់រដ្ឋ និងស្ថាប័នមិនមែនរដ្ឋាភិបាល ក្នុងការការពារនិងប្រឈមនឹងការបដិសេធន៍ ឧទាហរណ៍ខ្លះៗនៃការផ្តួចផ្តើម៖

- តុលាការប្រជាជនបដិវត្តន៍ បានបង្កើតឡើង រយៈពេលប្រាំពីរខែ នៅក្នុងឆ្នាំ១៩៧៩ ក្រោយរបបខ្មែរក្រហមដួលរលំ ដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ដោយកំបាំងមុខ ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។
- ឯកសារញត្តិរណសិរ្ស៖ ប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិត បានធ្វើញត្តិបណ្តឹងប្រហែល ១លាន៦សែន នៅចន្លោះឆ្នាំ១៩៨៣និង១៩៨៤ ដើម្បីជំរុញឲ្យអង្គការសហប្រជាជាតិទទួលស្គាល់ពីអំពើឃោរឃៅរបស់ខ្មែរក្រហម។ ញត្តិទាំងនោះ ពិពណ៌នាពីភាពឃោរឃៅប្រព្រឹត្តមកលើប្រជាជនកម្ពុជា វិធីសម្លាប់និងចំនួនមនុស្សដែលស្លាប់ ទីតាំងសម្លាប់ និងការរងទុក្ខវេទនារបស់ប្រជាជន។
- ទិវាជាតិនៃការចងចាំ (២០ ឧសភា) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៨៤ ដើម្បីជួយអ្នកនៅរស់ឲ្យទទួលនូវការផ្សះផ្សា និងនិយាយពីបទពិសោធន៍ឈឺចាប់របស់ខ្លួន។
- សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង The Tuol Sleng Genocide Museum និងវាលពិឃាតជើងឯក គឺជាទីតាំងនៃភស្តុតាងនៃការសម្លាប់ និងបំផ្លិចបំផ្លាញ និងជាទីកន្លែងដ៏សំខាន់នៃការចងចាំរួម។
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬតុលាការកាត់ក្តីខ្មែរក្រហម ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ នៅឆ្នាំ២០០៣ ដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តអំឡុងពេលពួកគេកាន់អំណាច។



Neak Ti Ream with her sister-in-law
(Credit: Family archive of Sayana Ser)



ភួយរបស់ នាក់ ទីរាម នៅសល់ពីសម័យខ្មែរក្រហម (រូបថតផ្តល់ដោយ៖ សើ សាយ្យាណា) (Credit: Sayana Ser)



Neak Ti Ream (center) with Sayana Ser (first right)
and her family (Credit: Family archive of Sayana Ser)

## ឧទាហរណ៍នៃការផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិល៖

- កម្មវិធីប្រវត្តិសាស្ត្រខ្មែរក្រហម The Khmer Rouge History Application បានបើកឲ្យដំណើរការប្រើប្រាស់នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៧ ដោយមជ្ឈមណ្ឌលបុប្ផាណា។ កម្មវិធីនេះអាចមានក្នុងឧបករណ៍ឆ្លាតវៃ ជួយឲ្យប្រជាជនក្មេងៗ សិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហម ប្រព័ន្ធយុត្តិធម៌ សិទ្ធិមនុស្ស និងសន្តិភាពពីអ្នករស់រានមានជីវិត។
- សៀវភៅកំណត់ហេតុរបស់ក្មេងស្រីម្នាក់ The Diary of a Young Girl ត្រូវបានហៅថា កំណត់ហេតុរបស់ អាន់ ហ្វ្រែង គឺជាកំណត់ហេតុភាសាហូឡង់ សរសេរដោយក្មេងស្រីជនជាតិជ្វីហ្វ ឈ្មោះ អាន់ ហ្វ្រែង Anne Frank អាយុ១៣ឆ្នាំ ពេលដែលនាងកំពុងរស់នៅលាក់ខ្លួនរយៈពេលពីរឆ្នាំជាមួយគ្រួសាររបស់នាង ក្នុងអំឡុងពេលពួកណាហ្ស៊ីកាន់កាប់ប្រទេសហូឡង់ Nazi occupation of the Netherlands ។ គ្រួសារនេះត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៤៤ និងត្រូវបញ្ជូនទៅជំរុំប្រមូលផ្តុំ និងសម្លាប់ **Auschwitz - Birkenau** ។ អាន់ ហ្វ្រែង ត្រូវបានបញ្ជូនទៅជំរុំប្រមូលផ្តុំ **Bergen - Belsen concentration** មួយទៀត ដែលនាងបានស្លាប់ទីនោះ ដោយជំងឺគ្រុនពោះវៀន នៅក្នុងឆ្នាំ១៩៤៥។ សំណេររបស់នាងត្រូវបានរក្សាទុកដោយពួកអ្នកជួយសង្គ្រោះ និងបានប្រគល់ឲ្យឪពុករបស់នាង ឈ្មោះ អូតូ ហ្វ្រែង ជាសមាជិកគ្រួសារតែម្នាក់គត់ដែលបានរស់រាន។ ចាប់តាំងពីពេលនោះមក កំណត់ហេតុរបស់ អាន់ ត្រូវបានបោះពុម្ពផ្សាយជាង៧០ភាសា។ នៅក្នុងឆ្នាំ២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជា Documentation Center of Cambodia បានបោះពុម្ពផ្សាយកំណត់ហេតុនេះ ជាភាសាខ្មែរ និងបានចែកចាយទៅតាមសាលានិងបណ្ណាល័យជាង២០០កន្លែង។ សៀវភៅកំណត់ហេតុនេះ បានបកប្រែដោយក្មេងស្រីមូស្លីមកម្ពុជាឈ្មោះ សើ សាយ្យាណា Sayana Ser ។
- នៅក្នុងឆ្នាំ២០១៩ សមាគម **NEVER AGAIN Association** និងមូលនិធិហេនរេចបូលកម្ពុជា **Heinrich Boell** បានរៀបចំកម្មវិធីសិក្ខាសាលាស្តីពីហូឡូខសត៍ ដំបូងមួយ ជាភាសាខ្មែរនិងអង់គ្លេស នៅទីក្រុងភ្នំពេញ។ ជាការបន្ត មូលនិធិហេនរេចបូលកម្ពុជា បានបោះពុម្ពសំណៅកំណែទី២នៃសៀវភៅកំណត់ហេតុរបស់ អាន់ ហ្វ្រែង ជាភាសាខ្មែរ នៅឆ្នាំ២០២១។

https://www.nigdywiecej.org/en/our-news/១៧៧-articles-from-២០១៩/៤២២៦-the-missing-picture-rethinking-genocide-studies-and-prevention





ស្ត្រីមូស្លីមនៅប្រទេសកម្ពុជា
(រូបថតផ្តល់ដោយ៖ សើ សាយ្យាណា)







អ្នកចូលរួមក្នុងសិក្ខាសាលាស្តីពីហូឡូខសត៍ ដែលរៀបចំដោយសមាគម NEVER AGAIN និង មូលនិធិហេនរិចបូលកម្ពុជា នៅភ្នំពេញ ខែកក្កដា ឆ្នាំ២០១៩ (ប្រភព៖ សមាគម NEVER AGAIN)



Participants of the seminar about the Holocaust in Phnom Penh, coorganised by the NEVER AGAIN Association and the Heinrich Boll Stiftung Cambodia, July ២០១៩ (Credit: NEVER AGAIN Association)

## សំណួរសម្រាប់ត្រិះរិះពិចារណា៖

១ តើសៀវភៅកំណត់ហេតុរបស់ក្មេងស្រីម្នាក់ មានចំណុចជាប់ទាក់ទងគ្នាចំពោះអ្នកអានកម្ពុជាដែរឬទេ?

២ តើរឿងរ៉ាវផ្ទាល់ខ្លួនអាចជំរុញលើកកម្ពស់សមាចិត្តរវាងក្រុមអ្នករងគ្រោះផ្សេងៗគ្នានៃអំពើប្រល័យពូជសាសន៍ដោយរបៀបណា?







ផ្នែកក្របខាងមុខនៃសៀវភៅកំណត់ហេតុរបស់ អាន់ ហ្វ្រែង ជាភាសាខ្មែរ (ឆ្នាំ២០០២ និង២០២០)



...8304 ថ្ងៃព្រហស្បតិ៍ ទី06 ខែសីហា ឆ្នាំ2020

**សៀវភៅកំណត់ហេតុរបស់ក្មេងស្រីអាន់ហ្វ្រែង ត្រូវបានបកប្រែបន្ថែមខ្លឹមសារជាភាសាខ្មែរលើកទី២**

ដោយៈ សៀវ

ភ្នំពេញៈ សៀវភៅកំណត់ហេតុរបស់ក្មេងស្រីម្នាក់ដែលមានឈ្មោះថា អាន់ហ្វ្រែង ត្រូវបានបកប្រែជាភាសាខ្មែរ បញ្ចូលខ្លឹមសារ ឯកសារបន្ថែមជាលើកទី២ ដើម្បីឱ្យអត្ថន័យ និងខ្លឹមសារសំខាន់ៗក្នុងសាច់រឿងឱ្យកាន់តែស៊ីជម្រៅ ដែលអ្នកអានបានទទួលបានទាំងភាពរីករាយ និងពិសេសបានទទួលសាច់រឿងថ្មីៗគ្រប់ជ្រុងជ្រោយបន្ថែមទៀត ។

កញ្ញាសើសាយ្យាណា ដែលជាអ្នកបកប្រែសៀវភៅ អាន់ហ្វ្រែង បានឱ្យដឹងថា សៀវភៅកំណត់ហេតុរបស់ក្មេងស្រីជនជាតិអាល្លឺម៉ង់ម្នាក់នេះ មានភាពល្បីល្បាញល្បោះណាស់ ដែលត្រូវបានគេបកប្រែជាង ៦០ភាសា ហើយត្រូវបានគេនិយមចូលចិត្តអានពាសពេញពិភពលោក ។

តទៅទំព័រ 86

សៀវភៅកំណត់ហេតុរបស់ក្មេងស្រី អាន់ ហ្វ្រែង

## TO BE COMPILED...

## Literature on the subject

*Chandler, David. (២០០៩). A History of Cambodia, Phnom Penh: Center for Khmer Studies*

*Chandler, David. (២000). Voices from S-២១: Terror and History in PolPot's Secret Prison. Chiang Mai: Silkworm Books.*

## *សទ្ទានុក្រមទាក់ទងនឹងហូឡូខសត៍*

***ការប្រឆាំងនឹងជនជាតិជ្វីហ្វ*៖** ជាការប្រកាន់ និងស្អប់ខ្ពើមចំពោះជនជាតិជ្វីហ្វ ជាសាសនា ឬក្រុមជាតិពន្ធ។ ការប្រឆាំងជនជាតិជ្វីហ្វ មានច្រើនទម្រង់ខុសៗគ្នា និងបានអភិវឌ្ឍតាម ពេលវេលា។ ឫសគល់នៃការប្រឆាំងនេះ មាននៅក្នុងការប្រឆាំងសាសនាយូដា។ លទ្ធិយូដា គឺជាជំនឿរបស់ជនជាតិជ្វីហ្វ និងជាសាសនាចាស់បំផុតដែលជឿលើឯកទិទេព។ ប្រវត្តិរបស់ប្រជាជនជ្វីហ្វ បានរស់នៅលើទឹកដីដែលគ្រប់គ្រងដោយក្រុមសាសនាផ្សេងៗ ដូចជាគ្រិស្តសាសនា។ ជ្វីហ្វតែងតែបានចាត់ទុកជា «អ្នកដទៃ» នៅក្នុងដែនដីទាំងនោះ។ ពួកគេមិនទទួលយកសាសនាគ្រិស្ត និងបានក្លាយជាអ្នករងកំហុសពីអកុសលភាពរបស់ សង្គមដែលពួកគេរស់នៅ។ ពាក្យចចាមអារាម រឿងប្រឌិត ព័ត៌មានមិនពិតអំពីជនជាតិកើត មានជាបន្តបន្ទាប់នៅក្នុងប្រវត្តិសាស្រ្ត។ ពួកគេព្យាយាមជំនះរហូតមកដល់សព្វថ្ងៃនេះ។ ការស្អប់ខ្ពើមជាញឹកញាប់នាំឲ្យកើតមានការរើសអើងនិងអំពើហិង្សា។ សម័យបច្ចុប្បន្ន ការប្រឆាំងពូជសាសន៍ គឺផ្អែកលើការស្អប់ខ្ពើមជនជាតិជ្វីហ្វ ដោយផ្អែកលើ «ជីវសាស្រ្ត» ខុសគ្នា ដោយត្រូវបានដាក់ជាពូជសាសន៍ដែល «អន់»។ លទ្ធិប្រឆាំងជនជាតិជ្វីហ្វ ផ្សាភ្ជាប់ទៅនឹងទ្រឹស្តីឃុបឃិត។ ពាក្យម្យ៉ាងទៀតដែលប្រើសម្រាប់លទ្ធិនេះ គឺអ្នកលុបបំបាត់ គឺសំដៅទៅការប្រឆាំងនឹងជនជាតិជ្វីហ្វរបស់ណាតហ្ស៊ី ដែលមាន គោលបំណងកម្ចាត់ជនជាតិជ្វីហ្វទាំងអស់។ លទ្ធិប្រឆាំងនឹងហ្សាយអឹន បរិយាយពីការស្អប់ខ្ពើមចំពោះជនជាតិជ្វីហ្វនៅរដ្ឋអ៊ីស្រា អែល។

***សូមមើល*** the IHRA definition of antisemitism

***ទ្រឹស្តីឃុបឃិតប្រឆាំងនឹងជនជាតិជ្វីហ្វ*៖** ការប្រឌិត និងកុហកថាជនជាតិជ្វីហ្វប្រើ អំណាចនិងឥទ្ធិពលរបស់ខ្លួនដើម្បីបោកប្រើ និងគ្រប់គ្រងរដ្ឋាភិបាលពិភពលោក។ ទ្រឹស្តី ឃុបឃិតទាំងអស់មានឫសគល់ពីលទ្ធិទំនើបដែលប្រឆាំងនឹងជនជាតិជ្វីហ្វ និងអរិភាព ចាស់។ ធាតុសំខាន់មួយនៃទ្រឹស្តីឃុបឃិតនេះ គឺការប្រមាថឈាម៖ ការចោទប្រកាន់ខុស ដែលថាជ្វីហ្វប្រើឈាមរបស់ក្មេងៗដែលមិនមែនជាជនជាតិជ្វីហ្វ ដើម្បីប្រារព្ធពិធី ហើយ ជាទូទៅប្រើឈាមរបស់ក្មេងជាគ្រិស្តសាសនិក។ ពាក្យចចាមអារាម អំពីការប្រមាថឈាម ត្រូវបានផ្សព្វផ្សាយទូលំទូលាយដោយពួកណាតហ្ស៊ី នៅអំឡុងពេលហូឡូខសត៍។ ឧទាហរណ៍នៃការប្រឌិតនេះ អាចរកឃើញនៅក្នុងសង្គមបច្ចុប្បន្នផងដែរ។

***ជំរំសម្លាប់ Auschwitz–Birkenau*៖** ជាជំរំប្រមូលផ្តុំ និងសម្លាប់ធំជាងគេ នៅក្នុងសង្រ្គាមលោកលើកទី២ (បច្ចុប្បន្នជាសារមន្ទីរ)។ បុរស ស្រ្តី កុមារជាង ១,១លាននាក់ ត្រូវបាត់បង់ជីវិតនៅទីនេះ។ ចាប់ពីពេលនោះមក វាបានក្លាយជានិមិត្តរូបចម្បងមួួយរបស់ ហូឡូខសត៍។

***អំណាចអាក់ស៊ីស*៖** សម្ព័ន្ធនយោបាយមួយដឹកនាំដោយអាល្លឺម៉ង់ អ៊ីតាលី និងជប៉ុន ដែលបានប្រឆាំងនឹងទ័ពសម្ព័ន្ធមិត្ត នៅក្នុងអំឡុងពេលសង្រ្គាមលោកលើកទី២។ សមាជិកផ្សេងទៀតរួមមាន ប្រទេសហុងការី រ៉ូម៉ានី ស្លូវ៉ាគី ប៊ុលការី ក្រូអាត និងហ្វាំងឡង់។

***អ្នកឈរមើល*៖** អ្នកដែលនៅអសកម្ម និងប្រងើយកន្តើយចំពោះការធ្វើទុកបុកម្នេញ ជនជាតិជ្វីហ្វ នៅអំឡុងពេលសង្រ្គាមលោកលើកទី២ ដោយមូលហេតុផ្សេងៗ។ អ្នកឈរ មើលមានបំណែកភាគច្រើននៅក្នុងសង្គម។ បុគ្គល និងក្រុមទាំងនេះ មិនចាំបាច់នៅក្នុង ប្រភេទតែមួយទេ នៅក្នុងហូឡូខសត៍ ពួកគេមានជម្រើសច្រើនសម្រាប់ពួកគេ។ ស្វែងយល់បន្ថែម៖ https://encyclopedia.ushmm.org/content/en/article/bystanders

***អ្នកចូលរួមសហការ*៖** ប្រទេសនៅអ៊ឺរ៉ុប នៅក្នុងអំណាចអាក់ស៊ីស បានសហ ប្រតិបត្តិការជាមួយរបបណាតហ្ស៊ីអាល្លឺម៉ង់ ដោយពង្រឹងច្បាប់ប្រឆាំងជនជាតិជ្វីហ្វ។ ***Vichy France*** ជាឈ្មោះដែលផ្តល់ឲ្យជាផ្លូវការទៅរដ្ឋសេរីបារាំង ដឹកនាំដោយ Marshal Philippe Pétain នៅអំឡុងពេល សង្រ្គាមលោកលើកទី២។ វាអនុវត្តតាមគោលនយោបាយសហការ ជាមួយណាតហ្ស៊ីអាល្លឺម៉ង់ ដែលកាន់កាប់នៅភាគខាងជើង និងខាងលិច។ នៅក្នុងប្រទេស ដែលកាន់កាប់ដោយអំណាចអាក់ស៊ីស មានជាបុគ្គលខ្លះ និងអង្គការចំនួន ដែលជំរុញទឹក ចិត្តដោយលទ្ធិជាតិនិយម លទ្ធិប្រឆាំងជនជាតិជ្វីហ្វ និងលទ្ធិប្រឆាំងកុម្មុយនីស្ត បានសហការជាមួយណាតហ្ស៊ី។

***ជំរំមរណៈ*៖** ណាតហ្ស៊ីបានសាងសង់ជំរំចំនួនប្រាំ នៅក្នុងប្រទេសប៉ូឡូញដែលខ្លួន កាន់កាប់ នៅចុងឆ្នាំ១៩៤១ និងដើមឆ្នាំ១៩៤២ ក្នុងបំណងសម្លាប់មនុស្សរកម្រិត ឧស្សាហកម្ម។ ជំរំ Belzec, Chelmno, Sobibor, Treblinka, Maidanek និង ជំរំ Auschwitz–Birkenau ត្រូវបានសាងសង់ដើម្បីសម្លាប់មនុស្សរាប់សែននាក់ ដោយប្រើឧស្ម័នម៉ូណូសាយ។ ជំរំទាំងនេះ មានទីតាំងនៅក្នុងតំបន់ព្រៃក្រាស់ៗ ដាច់ដោយឡែកពីពិភពខាងក្រៅ ប៉ុន្តែជាប់ផ្លូវ រទេះភ្លើង។

***លទ្ធិហ្វាស៊ីស***៖ មនោគមវិជ្ជានយោបាយ និងចលនាប្រមូលផ្តុំ ដែលរីករាលដាលនៅ ក្នុងបណ្តារប្រទេសនៃទ្វីបអឺរ៉ុបមួយចំនួន នៅចន្លោះឆ្នាំ១៩១៩ និង១៩៤៥។ វាបានជំរុញឲ្យ មានលទ្ធិយោធាជាតិនិយមហួសហេតុ វប្បធម៌តែមួយ និងអរិភាពចំពោះប្រជាធិបតេយ្យ។

***អំពើប្រល័យពូជសាសន៍***៖ មេធាវី Rafael Lemkin បានណែនាំពីទស្សនៈពាក្យ «ប្រល័យពូជសាសន៍» នៅក្នុងឆ្នាំ១៩៤៣។ ពាក្យនេះបានផ្អែកជាចម្បងទៅនយោបាយ របស់ណាតហ្ស៊ី ទៅចំពោះជ្វីហ្វ នៅអំឡុងពេលសង្គ្រាមលោកលើកទី២។ ទស្សនៈនេះ ត្រូវបានប្រើប្រាស់នៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការធ្វើទុកបុកម្នេញ និងទណ្ឌកម្មពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (១៩៤៨)។ ទស្សនៈនេះ បានបញ្ចូលនូវ អត្ថន័យទូលំទូលាយជាងទស្សនៈ «ហូឡូខស្ត៍» និងធំធេងជាងឧក្រិដ្ឋកម្មសម្លាប់។ អំពើប្រល័យពូជសាសន៍ គឺជាបំផ្លាញដោយចេតនា និងជាប្រព័ន្ធ ទាំងស្រុង ឬដោយផ្នែក នៃក្រុមជាតិពន្ធុ ពូជសាសន៍ សាសនា ជាតិ ឬវប្បធម៌ណាមួយ។ វាគឺជាឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិធំបំផុត។

***ហូឡូខស្ត៍***៖ គឺជាការធ្វើទុកបុកម្នេញជាប្រព័ន្ធគាំទ្រដោយរដ្ឋប្រទេស និងសម្លាប់ជនជាតិជ្វីហ្វនៅអឺរ៉ុប នៅចន្លោះឆ្នាំ១៩៣៣ និង១៩៤៥ ដោយរបបណាតហ្ស៊ី និងទ័ពសម្ព័ន្ធមិត្តដែលកាន់កាប់នៅអឺរ៉ុប។ អ្នកខ្លះឲ្យនិយមន័យពាក្យ «ហូឡូខស្ត៍» កាន់តែទូលំទូលាយ ដោយបញ្ចូលអ្នករងគ្រោះផ្សេងទៀតគឺ៖ ប្រជាជនពួករ៉ូម៉ា អ្នកស្រឡាញ់ភេទដូចគ្នា ជនពិការ និងក្រុមមនុស្សផ្សេងទៀត។ ពាក្យនេះ ត្រូវបានប្រើ ដោយអ្នករស់រានមានជីវិតពីហូឡូខស្ត៍ រ៉ូម៉ានី ឈ្មោះ Elie Wiese នៅដើមទសវត្សរ៍ឆ្នាំ ១៩៦០ ជាពាក្យប្រៀបធៀបតំណាងឲ្យការដុតបូជាមនុស្សទាំងស្រុង នៃជំរឹមរណៈរបស់ណាតហ្ស៊ី។ ***Shoah*** (ស្សូអាហ៍) គឺជាឈ្មោះភាសា ហ៊ីប្រឺ សម្រាប់ ហូឡូខស្ត៍ និងសំដៅតែទៅលើការសម្លាប់ជនជាតិជ្វីហ្វតែប៉ុណ្ណោះ។

***បដិសេធហូឡូខស្ត៍***៖ ជាបណ្តុំនៃការអះអាងខុស ថាហូឡូខស្ត៍មិនដែលកើតមាន និងថាជារឿងប្រឌិតឡើងទាំងស្រុង។ សូមមើល [International Holocaust Remembrance Alliance (IHRA) Working Definition of Holocaust Denial and Distortion.]

***ការបំផ្លៃងហូឡូខស្ត៍***៖ ជាការបង្ខូចទ្រង់ទ្រាយ និងប្រើល្បិចទាញប្រយោជន៍ពី ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រហូឡូខស្ត៍។ វាមានច្រើនប្រភេទ រួមមានការយល់ថាហូឡូខស្ត៍ ជារឿងឥតប្រយោជន៍ គ្មានតម្លៃខ្លឹមសារ និងមិនមានសារសំខាន់។

***សម្ព័ន្ធចងចាំហូឡូខស្ត៍អន្តរជាតិ (IHRA)***៖ ត្រូវបានស្គាល់ថាជា កងកម្លាំងកិច្ច សហការអន្តរជាតិ ស្តីពីការអប់រំអំពីហូឡូខស្ត៍ ការចងចាំ និងការស្រាវជ្រាវ (the ITF) រហូតដល់ខែមករា ឆ្នាំ២០១៣។ អង្គការអន្តររដ្ឋាភិបាលមួយនេះ បានបង្កើតឡើងក្នុងឆ្នាំ ១៩៩៨ ដែលប្រមូលផ្តុំដោយរដ្ឋាភិបាល និងអ្នកជំនាញ រួមគ្នាដើម្បីពង្រឹង និងលើកកម្ពស់ការ អប់រំអំពីហូឡូខស្ត៍ ការស្រាវជ្រាវ និងការចងចាំទូទាំងសកលលោក និងដើម្បីរក្សាការ ប្តេជ្ញាគាំទ្រដល់សេចក្តីប្រកាសនៃកិច្ចប្រជុំអន្តរជាតិស្តីពីហូឡូខស្ត៍ នៅទីក្រុងស្តុកខូម។

***លទ្ធិណាតហ្ស៊ីនិយម/ណាតហ្ស៊ី***៖ សង្គមជាតិនិយម (ភាសាអាល្លឺម៉ង់៖ Nationalsozialismus) គឺជាមនោគមវិជ្ជា និងការអនុវត្តន៍ទាក់ទងនឹងអាដូហ្វអ៊ីត្លែរ និង គណៈបក្សណាតហ្ស៊ី នៅអាល្លឺម៉ង់ណាហ្ស៊ី (១៩៣៣-១៩៤៥)។ វាជាទម្រង់មួយរបស់ ហ្វាស៊ីសនិយម ដែលប្រឆាំងនឹងប្រជាធិបតេយ្យសេរី និងប្រព័ន្ធរដ្ឋសភា។ លទ្ធិនេះ រួម បញ្ចូលនូវការប្រឆាំងពូជសាសន៍ជនជាតិជ្វីហ្វ ប្រឆាំងកុម្មុយនីស្ត និងប្រកាន់ពូជសាសន៍ បែបវិទ្យាសាស្ត្រ។

***ចលនាណាតហ្ស៊ីថ្មី***៖ គឺជាចលនាយោធា សង្គម និងនយោបាយ នៅក្រោយពេល សង្គ្រាម ដែលកោតសរសើរអ៊ីត្លែរ និងស្វែងរកការស្តារលទ្ធិណាតហ្ស៊ីឡើងវិញ។ ចលនា ណាតហ្ស៊ីថ្មីជំរុញការស្អប់ និងលើកតម្កើងពីឧត្តមភាពរបស់ស្បែកស។ វាគាំទ្រការវាយ ប្រហារផ្អែកពូជសាសន៍ និងជនជាតិភាគតិច រួមមាន ជនជាតិជ្វីហ្វ រ៉ូម៉ានី និងមូស្លីម។ ចលនានេះ អាចរកនៅក្នុងគ្រប់តំបន់នៃពិភពលោក។

***តុលាការ Nuremberg***៖ ធ្វើឡើងនៅចន្លោះពីឆ្នាំ១៩៤៥ និងឆ្នាំ១៩៤៦ កាត់ក្តីជនដៃ ដល់របស់ណាតហ្ស៊ីចំនួន២៤រូប ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ វាគឺជាតុលាការអន្តរជាតិដំបូងដែលធ្វើឡើងដោយ ប្រទេសសម្ព័ន្ធមិត្ត និងតំណាងប្រទេសដែលកាន់កាប់ដោយណាតហ្ស៊ី ដើម្បីប្រើជាយន្តការ ក្រោយសង្គ្រាម ដើម្បីនាំយកមេដឹកនាំជាតិមកកាត់ទោស ដោយការដាក់ពន្ធនាគារ ឬកាត់ ទោសប្រហារជីវិត។

***Porajamos*** ៖ ជាភាសារ៉ូមានី សម្រាប់ការប្រល័យពូជសាសន៍ដោយពួកណាតហ្ស៊ី ទៅ លើប្រជាជនរ៉ូម៉ានី និងស៊ិនទី ។ វាគឺជាពាក្យបង្កើតថ្មីដែលបកប្រែថា «លេបត្របាក់» ឬ «បំផ្លិចបំផ្លាញ» ។ ពួកណាតហ្ស៊ីបានចាត់ទុក ប្រជាជនរ៉ូម៉ា និងស៊ិនទី ជាអ្នកពូជសាសន៍អន់ និងប្រឆាំងសង្គម ។ យល់ដឹងបន្ថែម ៖ https://www.romarchive.eu/en/voices-of-the-victims/genocide-holocaust-porajmos-samudaripen

***ប្រតិបត្តិការ Reinhard*** ៖ គឺជាផែនការរបស់ណាតហ្ស៊ី ក្នុងការបំបាត់ប្រជាជនជ្វីហ្វនៅ ប្រទេសប៉ូឡូញ ។ យល់ដឹងបន្ថែម ៖ https://encyclopedia.ushmm.org/content/en/article/operation-reinhard-einsatz-reinhard

***សញ្ញា Swastika ៖*** ធ្លាប់ប្រើជានិមិត្តសញ្ញានៅក្នុងសាសនាព្រះពុទ្ធ និងហិណ្ឌូ ។ វាត្រូវបានប្រដូចនឹងលទ្ធិណាតហ្ស៊ី និងហូឡូខសត៍ ។

***សុចរិតត្រឹមត្រូវក្នុងចំណោមប្រជាជាតិ*** ៖ គឺជាអ្នកមិនមែនជ្វីហ្វដែលជួយជនជាតិ ជ្វីហ្វ ហើយត្រូវបានពួកណាតហ្ស៊ីធ្វើបាបក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ ។ អ្នក ជួយសង្គ្រោះជ្វីហ្វ អាចទទួលបានឋានៈជាមនុស្សសុចរិតក្នុងចំណោមប្រជាជាតិ (the Righteous Among the Nations) ពីមជ្ឈមណ្ឌល Yad Vashem នៅក្នុងប្រទេសអ៊ីស្រាអែល ។

***អ្នកក្រោកឈរ (Upstanders)*** ៖ គឺជាអ្នកដែលតស៊ូទប់ទល់នឹងសកម្មភាពរបស់ ជនដៃដល់ និង/ឬ បានជួយអ្នករងគ្រោះនៅក្នុងអំឡុងពេលសង្គ្រាមលោកលើកទី២ ។ ពាក្យនេះ អាចប្រើចំពោះស្ថានការណ៍ផ្សេងៗទៀត រួមទាំងពិភពសហកាល ។

***យុទ្ធនាការយើងចងចាំ (WeRemember Campaign)*** ៖ អង្គការសហប្រជាជាតិ បាន រៀបចំតាក់តែងដាក់យក ថ្ងៃទី២៧ ខែមករា ជាទិវាចងចាំអំពីហូឡូសត៍ ។ វាគឺជាថ្ងៃដែលជំរំមរណៈធំជាងគេ Auschwitz–Birkenau និងជំរំប្រមូលផ្តុំ ត្រូវបានរំដោះ ។ សមាជប្រជុំជ្វីហ្វ ពិភពលោក បានចាប់ផ្តើមដំណើរការយុទ្ធនាការ WeRemember ប្រចាំឆ្នាំ ដើម្បីរំឭកដល់ជន រងគ្រោះ ដោយកាន់សញ្ញាដែលអានថា ‘#WeRemember’ (យើងចងចាំ) និងដាក់រូបភាពរ បស់ពួកគេនៅក្នុងបណ្តាញសង្គម ។

"NEVER AGAIN"
ASSOCIATION

Copyright © 2022 NEVER AGAIN Association